( ឯកសារបកប្រែក្រៅផ្លូវការ )

# តុលាការយុត្តិធម៌អន្តរជាតិ ( ឡាអេ )

# រឿងក្តីប្រាសាទព្រះវិហារ
# ( កម្ពុជា ទល់នឹង ថៃ )
# អង្គសេចក្តី

# សាលដីកា
# ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២

( ឯកសារបកប្រែក្រៅផ្លូវការ )

# តុលាការយុត្តិធម៌អន្តរជាតិ ( ឡាអេ )

# រឿងក្តីប្រាសាទព្រះវិហារ
# ( កម្ពុជា ទល់នឹង ថៃ )
# អង្គសេចក្តី

# សាលដីកា
# ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២

សាលដីកានេះ

ត្រូវបានរៀបចំបោះពុម្ពតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់

របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

១៩៦២
១៥ មិថុនា
បញ្ជីលេខ៤៥

# តុលាការយុត្តិធម៌អន្តរជាតិ

## ឆ្នាំ១៩៦២

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២

## រឿងក្តីប្រាសាទព្រះវិហារ

(**កម្ពុជា** ទល់នឹង **ថៃ**)

## អង្គសេចក្តី

អធិបតេយ្យដែនដី។ - កម្មសិទ្ធិទទួលបានពីសន្ធិសញ្ញា។ - បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាបង្កើតនូវព្រំដែនដើរតាមខ្សែបែងចែកទឹក ដូចដែលត្រូវកំណត់ដោយគណៈកម្មការចម្រុះរបស់គូភាគី។ - លក្ខណៈមិនច្បាស់លាស់នៃលទ្ធផលកំណត់ព្រំដែននៅក្នុងតំបន់មានវិវាទ។ - ការបង្កើតផែនទីដោយអ្នកជំនាញនៃភាគីម្ខាង តាមសំណើរបស់ភាគីម្ខាងទៀត។ - ផែនទីដែលមានលក្ខណៈមិនចាប់បង្ខំនៅខណៈពេលដែលផែនទីនោះត្រូវបានបង្កើតឡើង។ - ការព្រមទទួលយកជាបន្តបន្ទាប់នូវផែនទីនិងខ្សែព្រំដែនតាមរយៈឥរិយាបថភាគីម្ខាងទៀត។ - អានុភាពគតិយុត្តនៃការស្ងៀមស្ងាត់ដែលត្រូវចាត់ទុកថាបានយល់ព្រមដោយតុណ្ហីភាព។ - ការអះអាងអំពីភាពមិនស្របគ្នានៃខ្សែព្រំដែននៅលើផែនទីជាមួយនឹងខ្សែបែងចែកទឹកជាក់ស្តែង។ - ការព្រមទទួលយកនូវហានិភ័យនៃការភាន់ច្រឡំ។ - ឥរិយាបថបន្តបន្ទាប់ដែលបញ្ជាក់នូវការទទួលយល់ព្រមពីដំបូងនិងដែលរារាំងមិនឱ្យបដិសេធការទទួលយល់ព្រមនោះវិញបាន។ - អានុភាពនៃសន្ធិសញ្ញាជាបន្តបន្ទាប់ដែលបញ្ជាក់នូវព្រំដែនដែលមានស្រាប់និងជាភស្តុតាងនៃបំណងចង់បានរបស់គូភាគីនូវព្រំដែនដែលមានស្ថិរភាពនិងស្ថាពរ។ - ការបកស្រាយអំពីដំណោះស្រាយក្នុងសន្ធិសញ្ញាត្រូវបានលើកមកពិចារណាទាំងស្រុង ដោយរួមទាំងផែនទីផងដែរ។

# **សាលដីកា**

វត្តមាន៖ លោក WINIARSKI ប្រធាន

លោក ALFARO អនុប្រធាន

លោក BASDEVANT, BADAWI, MORENO QUINTANA, WELLINGTON KOO, SIR PERCY SPENDER, SIR GERALD FITZMAURICE, KORETSKY, TANAKA, BUSTAMANTE Y RIVERO, MORELLI ចៅក្រម

លោក GARNIER-COIGNET ក្រឡាបញ្ជី។

## **ក្នុងរឿងក្តីប្រាសាទព្រះវិហារ**

រវាង

## **ព្រះរាជាណាចក្រកម្ពុជា**

**តំណាងដោយ៖**

- ឯកឧត្តម ទ្រឿង កាង សមាជិកឧត្តមក្រុមប្រឹក្សារាជបល្ល័ង្ក៖ ជាតំណាង

**និងដោយ៖**

- ឯកឧត្តម អ៊ុក ឈុំ អគ្គទីប្រឹក្សាអមស្ថានទូតកម្ពុជាប្រចាំនៅប្រទេសបារាំង

**ជួយដោយ៖**

- ឯកឧត្តម Dean Acheson សមាជិកគណៈមេធាវីនៃតុលាការកំពូលនៃសហរដ្ឋអាមេរិក
- លោក Roger Pinto សាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ទីក្រុងប៉ារីស
- លោក Paul Reuter សាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ទីក្រុងប៉ារីស

**ជាមេធាវី**

**និងដោយ៖**

- លោក Brice M. Clagett សមាជិកគណៈមេធាវីសាលាឧទ្ធរណ៍សហរដ្ឋអាមេរិកនៃក្រុងកូលូមប៊ី ( District of Columbia ) ជាទីប្រឹក្សាច្បាប់

- លោកវរសេនីយ៍ឯក ងិន ការ៉េត នាយកនៃនាយកដ្ឋានភូមិសាស្ត្រនៃកងយោធពលខេមរភូមិន្ទ ជាទីប្រឹក្សាឯកទេស
- លោក ចាន់ យ៉ូរ៉ាន់ ជាអគ្គលេខាធិការនៃគណៈប្រតិភូ
- លោក ចែម ស្ងួន ជាអគ្គលេខាធិការរងនៃគណៈប្រតិភូ

និង

## រាជាណាចក្រថៃ

### តំណាងដោយៈ

- ព្រះអង្គម្ចាស់ Vongsamahip Jayankura អគ្គរាជទូតថៃប្រចាំនៅប្រទេសហូឡង់ ជាតំណាង

### ជួយដោយៈ

- លោក Seni Pramoj សមាជិកគណៈមេធាវីនៃប្រទេសថៃ
- លោក Henri Rolin សាស្ត្រាចារ្យកិត្តិយសនៃ Free University of Brussels មេធាវីនៃសាលាឧទ្ធរណ៍ទីក្រុង Brussels
- ឯកឧត្តម Sir Frank Soskice, Q.C.,MP. អតីតអគ្គព្រះរាជអាជ្ញានៃប្រទេសអង់គ្លេស
- លោក James Nevins Hyde សមាជិកនៃគណៈមេធាវីនៃរដ្ឋ New York និងជាសមាជិកនៃគណៈមេធាវីនៃតុលាការកំពូលសហរដ្ឋអាមេរិក
- លោក Marcel Slusny មេធាវីនៃសាលាឧទ្ធរណ៍ទីក្រុង Brussels និងជាសាស្ត្រាចារ្យនៃ Free University of Brussels
- លោក J. G. Le Quesne សមាជិកគណៈមេធាវីនៃប្រទេសអង់គ្លេស

**ជាមេធាវីនិងទីប្រឹក្សាច្បាប់**

### និងដោយៈ

- ឧត្តមសេនីយ៍ឯក Busrindre Bhakdikul អគ្គនាយកនៃអគ្គនាយកដ្ឋានភូមិសាស្ត្រភូមិន្ទថៃនៃក្រសួងការពារជាតិ
- លោក Suk Perunavin អនុលេខាធិការរងនៃឧទ្ទកាល័យនាយករដ្ឋមន្ត្រី
- លោក Chinda Na Songkhla អគ្គលេខាធិការរងនៃគណៈកម្មការមុខងារសាធារណៈ

- លោកវររសេនីយ៍ទោ Phoon Phon Asanachinta សាស្ត្រាចារ្យនៃសាលឋានលេខាសាស្ត្រ អគ្គនាយកដ្ឋានភូមិសាស្ត្រភូមិន្ទថៃនៃក្រសួងការពារជាតិ

**ជាទីប្រឹក្សាឯកទេស**

**និងដោយៈ**

- លោក Chapikorn Sreshthaputra ប្រធាននាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានសន្ធិសញ្ញានិងនីតិកម្មនៃក្រសួងការបរទេស
- លោក David S. Downs មេធាវីតុលាការកំពូលប្រទេសអង់គ្លេស

**ជាទីប្រឹក្សាផ្នែកតុលាការ**

## តុលាការ

ដែលមានសមាសភាពដូចខាងលើ

វិនិច្ឆ័យសេចក្តីដូចខាងក្រោមៈ

តាមរយៈសាលដីកាចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៦១ តុលាការបានច្រានចោលនូវអញ្ញត្រកម្មបឋមទី១របស់រដ្ឋាភិបាលថៃ ហើយរកឃើញថាតុលាការនេះមានយុត្តាធិការវិនិច្ឆ័យលើវិវាទដែលបានដាក់ជូនតុលាការកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៥៩ តាមពាក្យសុំរបស់រដ្ឋាភិបាលកម្ពុជា។

តាមរយៈដីកាសម្រេចដែលមានកាលបរិច្ឆេទដូចគ្នា តុលាការបានសម្រេចកំណត់រយៈពេលសម្រាប់ដាក់ដំណើរការនីតិវិធីបន្ថែម។ សំណុំរឿងត្រូវបានរៀបចំរួចរាល់សម្រាប់ធ្វើសវនាការតាមការដាក់ជូននូវដំណើរការនីតិវិធីចុងក្រោយ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៦២។

សវនាការជាសាធារណៈត្រូវធ្វើឡើងតាមកាលបរិច្ឆេទដូចតទៅៈ ចាប់ពីថ្ងៃទី១ដល់ថ្ងៃទី៣ ខែមីនា, នៅថ្ងៃទី៥ ខែមីនា, ពីថ្ងៃទី៧ដល់ថ្ងៃទី១០ ខែមីនា, ពីថ្ងៃទី១២ដល់ថ្ងៃទី១៣ ខែមីនា, ពីថ្ងៃទី១៥ដល់ថ្ងៃទី១៧ ខែមីនា, ពីថ្ងៃទី១៩ដល់ថ្ងៃទី២៤ ខែមីនា និងពីថ្ងៃទី២៦ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៦២។ នៅក្នុងសវនាការទាំងនេះ តុលាការស្តាប់ទឡ្ហីករណ៍ និងការឆ្លើយតបផ្ទាល់មាត់របស់លោក ទ្រឿង កាង លោក Dean Acheson

លោក Roger Pinto និងលោក Paul Reuter តំណាងឱ្យរដ្ឋាភិបាលកម្ពុជា និងព្រះអង្គម្ចាស់ Vongsamahip Jayankura លោក Seni Pramoj លោក Henri Rolin, Sir Frank Soskice លោក James Nevins Hyde តំណាងឱ្យរដ្ឋាភិបាលថៃ។

នៅក្នុងសវនាការ ចាប់ពីថ្ងៃទី១៥ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦២ តុលាការបានស្តាប់សាក្សីនិងអ្នកជំនាញដែលបានកោះហៅដោយគូភាគីទាំងសងខាង ដើម្បីមកឆ្លើយនឹងសំណួរដែលសួរទៅពួកគេ ក្នុងការស្តាប់ចម្លើយនិងការសួរតទល់ដោយភាគីរបស់ខ្លួន និងដោយភាគីបដិបក្ខ និងដោយចៅក្រមតុលាការ។ សាក្សីដែលបានផ្តល់ភស្តុតាងមានរាយនាមដូចខាងក្រោម៖

កោះហៅដោយរដ្ឋាភិបាលកម្ពុជា៖

លោក សួន ប៊ុន អតីតអភិបាលខេត្តកំពង់ធំ អធិការផ្នែកកិច្ចការនយោបាយ និងរដ្ឋបាលនៃក្រសួងមហាផ្ទៃកម្ពុជា ជាសាក្សី។

កោះហៅដោយរដ្ឋាភិបាលថៃ៖

លោកសាស្ត្រាចារ្យ Willem Schermerhorn ព្រឹទ្ធបុរសនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិសម្រាប់វាស់វែងផែនទីដែនអាកាស Delft និងជានាយកនៃនាយកដ្ឋានប្រឹក្សាយោបល់សម្រាប់មជ្ឈមណ្ឌល ជាអ្នកជំនាញ។

លោក Friedrich E. Ackermann, Dipl. Ing ជាសាស្ត្រាចារ្យនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិសម្រាប់វាស់វែងផែនទីដែនអាកាស Delft និងជាសមាជិកនៃនាយកដ្ឋានប្រឹក្សាយោបល់សម្រាប់មជ្ឈមណ្ឌល ជាសាក្សីនិងជាអ្នកជំនាញ។

លោក Herman Theodoor Verstappen ជាអ្នកឯកទេសខាងភូមិសណ្ឋានវិទ្យា ប្រធានផ្នែកភូគព្ភសាស្ត្រនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលអន្តរជាតិសម្រាប់វាស់វែងផែនទីដែនអាកាស Delft ជាអ្នកជំនាញ។

នៅក្នុងសវនាការដែលត្រូវធ្វើនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៦២ តុលាការបានផ្អាក ហើយជួបប្រជុំគ្នាឡើងវិញជាអសាធារណៈនៅក្នុងបន្ទប់ ដើម្បីទស្សនាខ្សែភាពយន្តអំពីទីតាំងទំនាស់ដែលភាគីកម្ពុជាបានដាក់ជូន ដោយមានវត្តមានរបស់តំណាងភាគីទាំងសង

ខាង។ ក្នុងពេលនៃការបញ្ចាំងខ្សែភាពយន្តនោះ និងដោយមានការអនុញ្ញាតពីប្រធាន លោក សួន ប៊ុន បានបង្ហាញដោយសង្ខេបអំពីចំណុចទាំងឡាយដែលទាក់ទងទៅនឹងអង្គហេតុ។

នៅក្នុងដំណើរការនៃនីតិវិធីជាលាយលក្ខណ៍អក្សរ គូភាគីបានដាក់ជូននូវសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដូចខាងក្រោមនេះ៖

*តាងនាមឱ្យរដ្ឋាភិបាលកម្ពុជា៖*

នៅក្នុងបណ្តឹងនិងនៅក្នុងដំណើរការនីតិវិធី៖

"ទោះបីជារាជាណាចក្រថៃចូលខ្លួនឬមិនចូលខ្លួនក៏ដោយ សូមតុលាការមេត្តាធ្វើការវិនិច្ឆ័យនិងប្រកាសថា៖

(១) រាជាណាចក្រថៃ មានកាតព្វកិច្ចត្រូវដកចេញឱ្យអស់នូវកងកម្លាំងប្រដាប់អាវុធ ដែលខ្លួនបានបោះទីតាំងនៅវិកិណ្ណដ្ឋាននៃប្រាសាទព្រះវិហារ ចាប់តាំងពីឆ្នាំ១៩៥៤។

(២) អធិបតេយ្យដែនដីលើប្រាសាទព្រះវិហារ ជាកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជា។"

*នៅក្នុងការឆ្លើយតប៖*

"សូមតុលាការមេត្តា៖

I.- ច្រានចោលនូវសេចក្តីស្នើសុំឱ្យវិនិច្ឆ័យ ដែលដាក់ជូនដោយរាជាណាចក្រថៃនៅក្នុងដំណើរការនីតិវិធីតបរបស់ថៃ ជាពិសេសក្នុងករណីចាំបាច់ចំពោះការបង្ហាញនូវសំអាងហេតុនានា សម្រាប់ការបដិសេធនូវសេចក្តីស្នើសុំបន្ថែមនានាដែលនឹងអាចដាក់ជូនតុលាការដោយរាជាណាចក្រថៃជាយថាហេតុ។

II.- សម្រេចសេចក្តីតាមសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទាំងឡាយ ដែលមាននៅក្នុងបណ្តឹងផ្តើមនីតិវិធីនេះរបស់កម្ពុជា និងនៅក្នុងដំណើរការនីតិវិធីរបស់កម្ពុជា។

*សូមមេត្តាវិនិច្ឆ័យនិងប្រកាសថា៖*

១.- រាជាណាចក្រថៃ មានកាតព្វកិច្ចត្រូវដកចេញនូវកងកម្លាំងប្រដាប់អាវុធដែលខ្លួនបានបោះទីតាំងនៅវិកិណ្ណដ្ឋាននៃប្រាសាទព្រះវិហារ ចាប់តាំងពីឆ្នាំ១៩៥៤។

២.- អធិបតេយ្យដែនដីលើប្រាសាទព្រះវិហារ ជាកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជា។"

*តាងនាមឱ្យរដ្ឋាភិបាលថៃ៖*

នៅក្នុងដំណើរការនីតិវិធីតប៖

"រដ្ឋាភិបាលថៃស្នើសុំឱ្យវិនិច្ឆ័យថា៖

(១) ការទាមទាររបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងពាក្យបណ្ដឹងនិងដំណើរការនីតិវិធី មិនមានមូលដ្ឋានទេ និងគប្បីត្រូវបានច្រានចោល។

(២) ប្រាវិហានស្ថិតនៅក្នុងដែនដីនៃប្រទេសថៃ៖ សូមតុលាការជាទីគោរពមេត្តាធ្វើការវិនិច្ឆ័យសេចក្ដីនិងប្រកាសដូច្នេះ។"

នៅក្នុងពេលដំណើរការនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងពេលបិទសវនាការ នាថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៦២ មេធាវីនៃប្រទេសថៃបានស្នើសុំពន្យារពេលធ្វើសេចក្ដីស្នើសុំចុងក្រោយក្នុងនាមឱ្យប្រទេសថៃ រហូតដល់ក្រោយពេលស្ដាប់សាក្សីនិងអ្នកជំនាញ។ អ្នកតំណាងរបស់ភាគីកម្ពុជាត្រូវបានស្នើសុំឱ្យបង្ហាញទស្សនៈរបស់ខ្លួនអំពីបញ្ហានេះ និងបានប្រកាសថាខ្លួនមានការជឿជាក់ទាំងស្រុងលើភាពយុត្តិធម៌និងគតិបណ្ឌិតរបស់តុលាការ។ ក្រោយពីបានពិភាក្សាគ្នារួច តុលាការបានសម្រេចយល់ព្រមចំពោះការស្នើសុំសេចក្ដីអនុញ្ញាតដោយខ្លួនយល់ឃើញថា បន្ទាប់ពីបានស្ដាប់សាក្សីនិងអ្នកជំនាញ និងនៅមុនពេលដែលភាគីថៃធ្វើសេចក្ដីស្នើសុំចុងក្រោយ អ្នកតំណាងរបស់ភាគីកម្ពុជាអាចដាក់នូវសេចក្ដីកែលម្អនៃសេចក្ដីស្នើសុំរបស់ខ្លួន ប្រសិនបើខ្លួនមានបំណងចង់ធ្វើបន្ទាប់ពីបានស្ដាប់សាក្សីនិងអ្នកជំនាញទាំងនោះ។

សេចក្ដីស្នើសុំវិនិច្ឆ័យដែលដាក់ជូនតុលាការដោយគូភាគី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ហើយជាពិសេសបន្ទាប់ពីការសម្រេចខាងដើម មានដូចខាងក្រោម៖

*ភាគនាមឱ្យរដ្ឋាភិបាលកម្ពុជា៖*

**ក**. សេចក្ដីស្នើសុំឱ្យវិនិច្ឆ័យ ដែលត្រូវបានអាននាពេលធ្វើសវនាការថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៦២៖

"សូមតុលាការមេត្តា៖

១. វិនិច្ឆ័យសេចក្ដីនិងប្រកាសថា ខ្សែព្រំដែនរវាងកម្ពុជានិងថៃ នៅតំបន់ដងរែក គឺជាខ្សែដែលបានគូសនៅលើផែនទីរបស់គណៈកម្មការកំណត់ព្រំដែនរវាងឥណ្ឌូចិននិងសៀម (ឧបសម្ព័ន្ធ១ដែលមានភ្ជាប់នឹងដំណើរការនីតិវិធីរបស់ភាគីកម្ពុជា)។

២. វិនិច្ឆ័យសេចក្ដីនិងប្រកាសថា ប្រាសាទព្រះវិហារមានទីតាំងស្ថិតនៅក្នុងដែនដីក្រោមអធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា។

៣. វិនិច្ឆ័យសេចក្ដីនិងប្រកាសថា រាជាណាចក្រថៃមានកាតព្វកិច្ចត្រូវដកចេញនូវកងកម្លាំងប្រដាប់អាវុធ ដែលខ្លួនបានបោះទីតាំងនៅវិកិណ្ណដ្ឋាននៃប្រាសាទព្រះវិហារក្នុងដែនដីកម្ពុជា ចាប់តាំងពីឆ្នាំ១៩៥៤មក។

៤. វិនិច្ឆ័យសេចក្ដីនិងប្រកាសថា រាល់រូបចម្លាក់ សិលាចារឹក បំណែកនៃប្រាសាទ គំរូថ្មភក់និងកុលាលភាជន៍បុរាណ ដែលត្រូវបានយកចេញពីប្រាសាទដោយអាជ្ញាធរថៃ តាំងតែពីឆ្នាំ១៩៥៤ រដ្ឋាភិបាលថៃត្រូវតែប្រគល់មកឱ្យរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាវិញ។

**ខ**. សេចក្ដីស្នើសុំឱ្យវិនិច្ឆ័យ ដែលមានឈ្មោះថាសេចក្ដីស្នើសុំចុងក្រោយដែលត្រូវអាននៅក្នុងសវនាការ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦២

"សូមតុលាការមេត្តា៖

១. វិនិច្ឆ័យសេចក្ដីនិងប្រកាសថា ផែនទីតំបន់ដងរែក(ឧបសម្ព័ន្ធ១នៃដំណើរការនីតិវិធីរបស់ភាគីកម្ពុជា) បានត្រូវគូសឡើងនិងបោះពុម្ពផ្សាយក្នុងនាមនិងជាប្រយោជន៍ដល់គណៈកម្មការចម្រុះកំណត់ព្រំដែន ដែលបានបង្កើតឡើងដោយអនុសញ្ញាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ ថាផែនទីនេះ តំណាងឱ្យសេចក្ដីសម្រេចរបស់គណៈកម្មការខាងលើនេះ និងដោយសារហេតុការណ៍និងតាមហេតុផលនៃកិច្ចព្រមព្រៀងនិងឥរិយាបថបន្តបន្ទាប់របស់គូភាគី ថាផែនទីនេះមានលក្ខណៈជាសន្ធិសញ្ញា។

២. វិនិច្ឆ័យសេចក្តីនិងប្រកាសថា ខ្សែព្រំដែនរវាងកម្ពុជានិងថៃនៅក្នុងតំបន់ជម្លោះនេះក្នុងបរិវេណប្រាសាទព្រះវិហារ គឺជាខ្សែព្រំដែនដែលបានគូសនៅលើផែនទីរបស់គណៈកម្មការកំណត់ព្រំដែនរវាងឥណ្ឌូចិន-សៀម (ឧបសម្ព័ន្ធ ១ នៃដំណើរការនីតិវិធីរបស់កម្ពុជា)។

៣. វិនិច្ឆ័យសេចក្តីនិងប្រកាសថា ប្រាសាទព្រះវិហារមានទីតាំងស្ថិតនៅក្នុងដែនដីក្រោមអធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា។

៤. វិនិច្ឆ័យនិងប្រកាសថា រាជាណាចក្រថៃមានកាតព្វកិច្ចត្រូវដកចេញនូវកងកម្លាំងប្រដាប់អាវុធ ដែលខ្លួនបានបោះទីតាំងនៅវិកិណ្ណដ្ឋាននៃប្រាសាទព្រះវិហារនៅក្នុងដែនដីកម្ពុជា ចាប់តាំងពីឆ្នាំ១៩៥៤មក។

៥. វិនិច្ឆ័យសេចក្តីនិងប្រកាសថា រាល់រូបចម្លាក់ សិលាចារឹក បំណែកនៃប្រាសាទគំរូថ្មភក់និងកុលាលភាជន៍បុរាណ ដែលត្រូវបានយកចេញពីប្រាសាទដោយអាជ្ញាធរថៃ តាំងតែពីឆ្នាំ១៩៥៤ រដ្ឋាភិបាលថៃត្រូវតែប្រគល់មកឱ្យរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាវិញ។"

### *តាងនាមឱ្យរដ្ឋាភិបាលថៃ ៖*

**គ**. សេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលត្រូវបានអាននៅក្នុងសវនាការថ្ងៃទី២០ ខែមីនាឆ្នាំ១៩៦២

"ពាក់ព័ន្ធនឹងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលបានដាក់ដោយរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៦២ រដ្ឋាភិបាលថៃសូមដាក់ជូនតុលាការនូវសេចក្តីស្នើសុំឱ្យវិនិច្ឆ័យរបស់ខ្លួន ដូចខាងក្រោម៖

១. សូមតុលាការមេត្តាកុំទទួលយកមកពិចារណាលើការទាមទារ ដែលបានស្នើដោយភាគីកម្ពុជា នៅក្នុងកថាខណ្ឌទី១និងទី៤ នៃសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលដាក់ជូនដោយអ្នកតំណាងរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃច័ន្ទ ទី៥ ខែមីនា ដោយហេតុថាការទាមទារទាំងពីរនេះត្រូវបានដាក់យឺតពេលពេក ហើយមិនបានបញ្ចូលទៅក្នុងការទាមទារទាំងឡាយ ដែលរដ្ឋាភិបាលកម្ពុជាបានមានបំណងដាក់ជូនតុលាការនៅក្នុងបណ្តឹងផ្តើមនីតិវិធីនេះ ឬក្នុងដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរ ហើយនេះគឺជាលើកដំបូងដែលអ្នកតំណាងរបស់កម្ពុជាលើកឡើងនៅពេល

ដែលគាត់បានធ្វើសេចក្ដីស្នើសុំរបស់កម្ពុជា។ ហេតុដូច្នេះភាគីថៃសូមស្នើតុលាការថាមិនគួរទទួលយកការទាមទារទាំងនេះមកពិចារណាទេ។

២. ជាជំនួសវិញ

"ពាក់ព័ន្ធនឹងការទាមទារទី១ នៃការទាមទារទាំងឡាយខាងលើនេះ ភាគីថៃសូមដាក់ជូននូវសេចក្ដីសន្និដ្ឋានដូចខាងក្រោម៖

(i) គេមិនអាចបញ្ជាក់បានថា ផែនទីឧបសម្ព័ន្ធ១ ជាឯកសារដែលតម្រូវឱ្យភាគីទាំងអស់គោរពតាមនោះទេ បើទោះបីជាតាមខ្លឹមសារនៃអនុសញ្ញាឆ្នាំ១៩០៤ ឬតាមហេតុផលផ្សេងពីនេះក៏ដោយ ។

(ii) តាមពិត ប្រទេសថៃនិងប្រទេសកម្ពុជាពុំបានចាត់ទុកព្រំដែនដែលបានគូសនៅលើឧបសម្ព័ន្ធ១ ជាព្រំដែនរវាងប្រទេសថៃនិងប្រទេសកម្ពុជា នៅក្នុងតំបន់ភ្នំដងរែកទេ។

(iii) ដោយសារហេតុផលទាំងឡាយខាងលើនេះ ខ្សែព្រំដែនដែលបានគូសនៅក្នុងឧបសម្ព័ន្ធ១ មិនគួរយកមកជំនួសខ្សែព្រំដែនដែលមានស្រាប់នៅតាមជួរភ្នំដងរែកនោះទេ ដែលតាមពិតត្រូវបានភាគីទាំងពីរធ្វើការកត់សម្គាល់និងទទួលយករួចហើយ។

(iv) ដូច្នេះ ទោះបីជាតុលាការយល់ឃើញថា សមស្របនឹងទទួលយកមកពិចារណានូវការទាមទារ (I) ខាងលើនាពេលនេះ ដែលស្នើឡើងដោយកម្ពុជា ផ្ទុយនឹងសេចក្ដីស្នើសុំឱ្យវិនិច្ឆ័យរបស់ថៃក៏ដោយ ក៏ថៃសូមស្នើថា ការទាមទារនេះមិនមានមូលដ្ឋានគ្រប់គ្រាន់ទេ ផ្អែកតាមអង្គសេចក្ដី ហើយគប្បីបដិសេធចោល។

៣. សូមដាក់ជូនសេចក្ដីស្នើសុំបន្ថែមដូចខាងក្រោម ដើម្បីឆ្លើយតបនឹងសេចក្ដីស្នើសុំឱ្យវិនិច្ឆ័យទី២និងទី៣របស់កម្ពុជា៖

(i) មានភស្ដុតាងជាច្រើនបង្ហាញថា គ្រប់ពេលវេលាសំខាន់ៗទាំងអស់ ថៃបានអនុវត្តអធិបតេយ្យពេញលេញក្នុងតំបន់ប្រាសាទនេះ ដោយគ្មានកម្ពុជា។ ផ្ទុយទៅវិញ ប្រសិនបើអធិបតេយ្យនេះត្រូវបានបដិសេធ

ហើយប្រសិនបើកម្ពុជាបានអនុវត្តមុខងាររដ្ឋបាលរបស់ខ្លួនណាមួយនៅក្នុងតំបន់ខាងលើ សកម្មភាពបែបនោះមានលក្ខណៈម្តងម្កាលនិងមិនប្រាកដប្រជា ហើយទោះស្ថិតក្នុងករណីណាក៏ដោយ ក៏មិនអាចលុបចោល ឬកម្រិតការអនុវត្តអធិបតេយ្យពេញលេញរបស់ថៃនៅក្នុងតំបន់ខាងលើនេះបានឡើយ។

(ii) ខ្សែបែងចែកទឹកនៅក្នុងតំបន់ខាងលើ ស្របគ្នាភាគច្រើននឹងចំណោតថ្មជុំវិញប្រាសាទព្រះវិហារ និងបង្កើតបានជាព្រំដែនតាមសន្ធិសញ្ញានៅក្នុងតំបន់ខាងលើនេះ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ១៩០៤។

(iii) នៅក្នុងកម្រិតដែលថា គែមចំណោតថ្មមិនស្របគ្នាទាំងស្រុងទៅនឹងខ្សែបែងចែកទឹកដូចបានបង្ហាញឱ្យឃើញដោយសណ្ឋានដីនៅក្នុងតំបន់នេះ ភាពខុសគ្នានៃបម្រែបម្រួលមានកម្រិតតិចតួចប៉ុណ្ណោះ ហើយមិនគួរយកមកពិចារណាទេ។

(iv) លក្ខណៈទូទៅនៃតំបន់នោះ អនុញ្ញាតឱ្យមានច្រកចូលទៅកាន់ប្រាសាទពីខាងប្រទេសថៃ រីឯច្រកចូលប្រាសាទពីខាងប្រទេសកម្ពុជា ត្រូវឡើងកាត់ចំណោតភ្នំខ្ពស់ ពីវាលទំនាបកម្ពុជា។

(v) ក្នុងកាលៈទេសៈនៃរឿងក្តីនេះ គេមិនអាចអនុវត្តដើម្បីជាប្រយោជន៍ដល់កម្ពុជានូវលទ្ធិណាមួយ ដែលលើកឡើងដោយមេធាវីកម្ពុជាឡើយ មិនថាជាការយល់ព្រម (acquiescence) ការមិនប្រែក្រឡះសម្តី (estoppel) ឬអាជ្ញាយុកាល (prescription) នោះទេ។

(vi) ទោះក្នុងករណីណាក៏ដោយ តុលាការមិនគួរអនុញ្ញាតឱ្យកម្ពុជាដាក់ស្នើសុំការទាមទារមួយ ដោយផ្អែកលើអាជ្ញាយុកាលដែលពុំមានលើកឡើងនៅកន្លែងណាមួយសោះ នៅក្នុងដំណើរការនីតិវិធីរបស់ខ្លួន ឬរហូតដល់ជិតចុងបញ្ចប់នៃការបង្ហាញហេតុផលដោយផ្ទាល់មាត់របស់ខ្លួន ទើបលើកឡើងនូវការទាមទារបែបនេះ។

(vii) ទោះក្នុងករណីណាក៏ដោយ ភស្តុតាងដែលជាប្រយោជន៍ដល់កម្ពុជា មិនគ្រប់គ្រាន់ទាំងស្រុង ដើម្បីផ្តល់ឱ្យកម្ពុជានូវកម្មសិទ្ធិដោយអាជ្ញាយុកាលនោះទេ។
ដូច្នេះ សេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី២និងទី៣ របស់កម្ពុជាគួរត្រូវបដិសេធចោល។

៤. បន្ថែមនិងជំនួសឱ្យសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី៤របស់កម្ពុជា ភាគីថៃសូមស្នើថា សេចក្តីស្នើសុំឱ្យវិនិច្ឆ័យនេះ បើទុកជាតុលាការទទួលយកមកពិចារណា ក៏ពុំមានភស្តុតាងគាំទ្រទាល់តែសោះ ដូច្នេះហើយការទាមទារដាក់ជូនដោយភាគីកម្ពុជានៅក្នុងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី៤នេះមិនអាចគាំទ្របានទេ។"

**ខ**. សេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលបានកែសម្រួល ត្រូវបានដាក់ជូននៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦២ បន្ទាប់ពីសវនាការ។

"ពាក់ព័ន្ធនឹងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យ ដែលបានកែសម្រួលដាក់ជូនដោយរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦២ រដ្ឋាភិបាលថៃសូមគោរពដាក់សេចក្តីស្នើសុំឱ្យវិនិច្ឆ័យជូនតុលាការដូចខាងក្រោម៖

*I. ពាក់ព័ន្ធនឹងការទាមទារទី១នៃសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលបានកែសម្រួល៖*

១. ភស្តុតាងទាំងមូលនៅចំពោះមុខតុលាការបង្ហាញថា ផែនទីនៅក្នុងតំបន់ភ្នំដងរែក ដែលជាឧបសម្ព័ន្ធ១នៃដំណើរការនីតិវិធីរបស់កម្ពុជាមិនត្រូវបានគេរៀបចំឬបោះពុម្ពផ្សាយ ក្នុងនាមនិងជាប្រយោជន៍ដល់គណៈកម្មការចម្រុះកំណត់ព្រំដែនដែលត្រូវបានបង្កើតឡើងតាមអនុសញ្ញា ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ ទេ។ ដោយឡែក គណៈកម្មការចម្រុះខាងលើ រួមមានគណៈកម្មការបារាំង និងគណៈកម្មការសៀម ក៏ប៉ុន្តែឧបសម្ព័ន្ធ១ខាងលើត្រូវបានរៀបចំឡើងដោយ សមាជិកគណៈកម្មការបារាំងតែម្នាក់ឯង និងត្រូវបានបោះពុម្ពផ្សាយតែក្នុងនាមគណៈកម្មការបារាំងតែម្នាក់ឯងប៉ុណ្ណោះ។
២. មន្ត្រីបារាំងដែលបានរៀបចំឧបសម្ព័ន្ធ១ខាងលើ ពុំមានអំណាចអ្វីផ្តល់ការបកស្រាយផ្លូវការឬចុងក្រោយណាមួយអំពីសេចក្តីសម្រេចរបស់គណៈកម្មការ

ចម្រុះខាងលើនោះទេ ហើយរឹតតែពុំមានអំណាចក្នុងការបកស្រាយគោលបំណង របស់គណៈកម្មការចម្រុះខាងលើ នៅត្រង់ចំណុចដែលពុំមានសេចក្តីសម្រេច ណាមួយត្រូវបានកត់ត្រាទុកនោះទេ។

៣. គ្មានសេចក្តីសម្រេចរបស់គណៈកម្មការចម្រុះខាងលើត្រូវបានកត់ត្រាទុក អំពីព្រំដែននៅប្រាសាទទេ។ ប្រសិនបើគណៈកម្មការចម្រុះខាងលើពិតជាបាន ឈានទៅដល់សេចក្តីសម្រេចបែបណានោះ សេចក្តីសម្រេចនោះមិនមែនជា តំណាងត្រឹមត្រូវនៅលើឧបសម្ព័ន្ធ១ខាងលើនេះទេ ប៉ុន្តែគឺជាសេចក្តីសម្រេច ដែលថា នៅក្នុងតំបន់ប្រាសាទ ព្រំដែនគួរត្រួតស៊ីគ្នាជាមួយនឹងគែមចំណោតថ្ម។

៤. ពុំមានកិច្ចព្រមព្រៀងក្រោយៗមកទៀតរបស់គូភាគីដែលផ្តល់ឱ្យឧបសម្ព័ន្ធ១ នូវលក្ខណៈជាទ្វេភាគីឬជាអនុសញ្ញាទេ។

៥. ឥរិយាបថរបស់គូភាគី ចំពោះលក្ខណៈជាអនុសញ្ញារបស់ឧបសម្ព័ន្ធ១ខាងលើ បង្ហាញថា ភាគីទាំងពីរពុំបានចាត់ទុកខ្សែព្រំដែនដែលបានគូសនៅលើឧបសម្ព័ន្ធ១ ជាខ្សែព្រំដែននៅភ្នំដងរែកឡើយ។ ថៃបានបន្តការកាន់កាប់ដោយគ្មានជម្លោះនៅ លើទឹកដីទាំងអស់នៅលើកំពូលភ្នំដងរែក។ នៅទីកន្លែងណាក៏ដោយ ដែលមាន គែមចំណោតថ្មលើភ្នំដងរែក គែមចំណោតថ្មនេះនឹងត្រូវបានទទួលយកជាព្រំដែន ខ្សែបែងចែកទឹក ដែលត្រូវបានបង្កើតឡើងនៅក្នុងតំបន់នេះតាមមាត្រា១នៃអនុ សញ្ញាឆ្នាំ១៩០៤។

៦. បើទោះបីជាឧបសម្ព័ន្ធ១ខាងលើនេះ ត្រូវបានចាត់ទុកថាមានលក្ខណៈជា អនុសញ្ញាក៏ដោយ ក៏ខ្សែព្រំដែនដែលបានគូសនៅលើផែនទីឧបសម្ព័ន្ធ១នេះនឹង មិនតម្រូវឱ្យគូភាគីគោរពតាមឡើយ ពីព្រោះថា - ស្ថិតនៅក្នុងតំបន់ជម្លោះនេះ - វាផ្អែកទៅលើការវាស់វែងមិនសុក្រឹតនៅលើដីជាក់ស្តែង។

*II. ពាក់ព័ន្ធនឹងការទាមទារទី២នៃសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលបានកែសម្រួល*

១. សូមតុលាការកុំទទួលយកមកពិចារណានូវការទាមទារនេះ ពីព្រោះថា៖

(i) ការទាមទារចំពោះតំបន់ "នៅក្នុងបរិវេណប្រាសាទប្រាសាទ" គឺជាការ ពង្រីកការទាមទារ ដែលរដ្ឋាភិបាលកម្ពុជាបានដាក់ជូននៅក្នុងបណ្តឹង ផ្តើមនីតិវិធីនេះ និងនៅក្នុងដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរ។

(ii) លក្ខខណ្ឌនៃការទាមទារមានភាពមិនច្បាស់លាស់ ដើម្បីឱ្យតុលាការ និងរដ្ឋាភិបាលថៃអាចកំណត់បាននូវទំហំទឹកដីដែលត្រូវទាមទារនោះ។

២. ជាជំនួសវិញ រដ្ឋាភិបាលថៃសូមលើកឡើងម្តងទៀតនូវកថាខណ្ឌ៣នៃសេចក្តីស្នើសុំឱ្យវិនិច្ឆ័យរបស់ខ្លួន ដែលបានដាក់ជូនកាលពីសវនាការរបស់តុលាការនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦២។

*III. ចំពោះការទាមទារទី៣និងទី៤នៃសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលបានកែសម្រួល*

រដ្ឋាភិបាលថៃ សូមលើកឡើងម្តងទៀតនូវកថាខណ្ឌ៣នៃសេចក្តីស្នើសុំឱ្យវិនិច្ឆ័យរបស់ខ្លួនដែលបានដាក់ជូនកាលពីសវនាការរបស់តុលាការ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៦២។

*IV. ចំពោះការទាមទារទី៥នៃសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលបានកែសម្រួល*

១. សូមតុលាការកុំទទួលយកមកពិចារណាលើការទាមទារនេះ ពីព្រោះការទាមទារនេះ ពង្រីកពីលើការទាមទារដែលរដ្ឋាភិបាលកម្ពុជាបានដាក់ជូននៅក្នុងបណ្តឹងផ្តើមនីតិវិធីនិងនៅក្នុងដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរ។

២. ជាជំនួសវិញ ការច្រានចោលនូវការទាមទារទី១ ទី២ និងទី៣នៃសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលបានកែសម្រួល ត្រូវតែនាំទៅដល់ការច្រានចោលនូវការទាមទារនេះ។

៣. ជាជំនួសវិញ ការទាមទារនេះគួរកំណត់ចំពោះតែវត្ថុទាំងឡាយតាមប្រភេទដែលត្រូវបញ្ជាក់នៅក្នុងការទាមទារ ដែលត្រូវបញ្ជាក់ដោយភស្តុតាងនៅចំពោះមុខតុលាការថា អាជ្ញាធរថៃបានយកចេញពីប្រាសាទ ចាប់តាំងពីឆ្នាំ១៩៥៤។"

*

* *

នៅក្នុងសាលដីការបស់ខ្លួនចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៦១ ដែលតាមរយៈសាលដីកានេះ តុលាការបានទទួលស្គាល់សមត្ថកិច្ចរបស់ខ្លួន ដើម្បីវិនិច្ឆ័យលើជម្លោះដែលរដ្ឋាភិបាលកម្ពុជាបានប្តឹងមកតុលាការ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៥៩ តុលាការបានកំណត់ចំណុចវិវាទដូចខាងក្រោមនេះ ៖

"នៅក្នុងសំណុំរឿងនេះ កម្ពុជាបានចោទប្រកាន់ការរំលោភបំពានដោយភាគីថៃលើអធិបតេយ្យទឹកដីរបស់កម្ពុជានៅតំបន់ប្រាសាទព្រះវិហារ និងបរិវេណជុំវិញប្រាសាទ។ ថៃឆ្លើយតបវិញដោយបញ្ជាក់អះអាងថា តំបន់ដែលមានបញ្ហាស្ថិតនៅខាងថៃនៃព្រំដែនរួមរវាងប្រទេសទាំងពីរ ហើយស្ថិតនៅក្រោមអធិបតេយ្យរបស់ថៃ។ នេះគឺជាជម្លោះអំពីអធិបតេយ្យដែនដី។"

ដូច្នេះ ចំណុចវិវាទដែលមាននៅចំពោះមុខតុលាការគឺការយល់ឃើញខុសគ្នាអំពីអធិបតេយ្យលើតំបន់នៃប្រាសាទព្រះវិហារ។ ដើម្បីដោះស្រាយបញ្ហាអធិបតេយ្យដែនដីនេះ តុលាការត្រូវតែពិនិត្យមើលខ្សែព្រំដែនរវាងរដ្ឋទាំងពីរនៅក្នុងតំបន់នោះ។ តុលាការបានទទួលផែនទីជាច្រើន ហើយក៏បានធ្វើការពិចារណាមួយចំនួនរួចហើយពាក់ព័ន្ធនឹងបញ្ហានេះ។ តុលាការនឹងពិនិត្យពិចារណាលើផែនទីនីមួយៗនៃផែនទីទាំងនេះ តែក្នុងក្របខណ្ឌដែលតុលាការអាចរកឃើញអំពីមូលហេតុនានា ដែលមាននៅក្នុងផែនទីសម្រាប់ធ្វើការសម្រេចសេចក្តី ដើម្បីដោះស្រាយជម្លោះតែមួយគត់ដែលបានដាក់ជូនមកតុលាការ ហើយដែលចំណុចវិវាទនេះទើបតែត្រូវបានលើកឡើងខាងលើ។

*

*   *

ប្រាសាទព្រះវិហារ គឺជាបដិសរណដ្ឋានពិសិដ្ឋនិងជាទីសក្ការៈបុរាណមួយ ដែលស្ថិតនៅព្រំដែនថៃ-កម្ពុជា។ បច្ចុប្បន្ន ទោះបីជាផ្នែកខ្លះត្រូវបានបែកបាក់ក៏ដោយ ក៏ប្រាសាទមានផលប្រយោជន៍ផ្នែកសិល្បៈ និងបុរាណវិទ្យាយ៉ាងសម្បើម ហើយនៅតែប្រើប្រាស់ជាកន្លែងធម្មយាត្រា។ ប្រាសាទនេះតាំងនៅលើពយភ្នំខ្ពស់ដែលមានឈ្មោះដូចគ្នា ស្ថិតនៅតំបន់ខាងកើតនៃជួរភ្នំដងរែក ដែលជាធម្មតាបង្កើតបានជាព្រំប្រទល់រវាងប្រទេសទាំងពីរនៅក្នុងតំបន់នេះ គឺប្រទេសកម្ពុជានៅខាងត្បូងនិងប្រទេសថៃនៅខាងជើង។ ផ្នែកជាច្រើននៃជួរភ្នំនេះ រួមផ្សំដោយផ្ទាំងថ្មចោតខ្ពស់ៗឡើងត្រង់ពីលើវាលទំនាបរបស់ប្រទេសកម្ពុជា។ នេះគឺជាស្ថានភាពនៅព្រះវិហារតែម្តង ដែលអគារប្រាសាទធំស្ថិតនៅត្រង់កំពូលនៃទីខ្ពស់រាងត្រីកោណលយចេញទៅរកតំបន់ទំនាប។ ចាប់ពីគែមនៃចំណោតខ្ពស់ ស្ថានភាពទូទៅ

នៃផ្ទៃដីមានលក្ខណៈជាជម្រាលឆ្ពោះទៅទិសខាងជើងរហូតដល់ទន្លេណាមមូន ដែលស្ថិតនៅក្នុងប្រទេសថៃ។

តាមការពិពណ៌នាខាងលើ គឺជាក់ស្តែងណាស់ថាខ្សែព្រំដែនដែលដើរតាមបណ្តោយគែមចំណោតថ្មឬទោះបីជាក្នុងកម្រិតណាមួយក៏ដោយ បើវាដើរទៅទិសខាងត្បូងនិងខាងកើតនៃតំបន់ប្រាសាទ នោះតំបន់នេះនឹងស្ថិតនៅក្នុងប្រទេសថៃ។ ផ្ទុយទៅវិញ បើខ្សែព្រំដែនដើរទៅទិសខាងជើងឬទៅទិសខាងជើងនិងខាងលិច នោះតំបន់ប្រាសាទព្រះវិហារនឹងស្ថិតនៅក្នុងប្រទេសកម្ពុជា។

ប្រទេសថៃបានទទូចថា គែមនៃចំណោតថ្មបង្កើតបានជាខ្សែព្រំដែនធម្មជាតិនិងជាក់ស្តែងនៅក្នុងតំបន់នេះ។ ដើម្បីគាំទ្រការអះអាងនេះ ប្រទេសថៃបានយោងទៅដល់ភស្តុតាងជាឯកសារដែលបញ្ជាក់ពីឆន្ទៈរបស់ភាគីទាំងពីរ ក្នុងការបង្កើតខ្សែព្រំដែនដែលនឹងមិនត្រឹមតែមានលក្ខណៈធម្មជាតិប៉ុណ្ណោះទេ គឺថែមទាំងជាក់ស្តែងនិងមិនអាចភាន់ច្រឡំទៀតផង ដូចជាទន្លេ ជួរភ្នំ និងចំណោតថ្មខ្ពស់ដែលមានស្រាប់នេះ។

ឆន្ទៈរបស់ភាគីទាំងពីរដែលចង់បានខ្សែព្រំដែនមួយ ដែលមានលក្ខណៈធម្មជាតិនិងជាក់ស្តែង អាចឆ្លើយតបបានតាមស្ទើរតែគ្រប់ខ្សែបន្ទាត់ណាមួយ ដែលដើរតាមគន្លងដែលអាចសម្គាល់បានតាមបណ្តោយជួរភ្នំសំខាន់នៃជួរភ្នំដងរែក។ ព្រំដែនអាចនឹងដើរតាមខ្សែបន្ទាត់កំពូលភ្នំ ខ្សែបែងចែកទឹក ឬខ្សែចំណោតភ្នំមួយ (នៅទីណាដែលមានចំណោតភ្នំហើយដែលករណីនេះស្ទើរតែគ្មាន)។ ដូចដែលគេបានឃើញនាពេលបច្ចុប្បន្ននេះ ភាគីទាំងពីរបានសម្រេចយកខ្សែបែងចែកទឹក។ ធ្វើបែបនេះ គេសន្មតថាភាគីទាំងពីរបានទទួលដឹងឮថា ខ្សែបន្ទាត់បែបនេះ ទោះស្ថិតក្នុងទីតាំងជាក់លាក់ណាមួយក៏ដោយ នឹងមិនមែនចាំបាច់ថា ជាខ្សែបន្ទាត់ដូចគ្នាទៅនឹងខ្សែបន្ទាត់តាមកំពូលភ្នំឬចំណោតថ្មនោះទេ។ ដូច្នេះគេមិនអាចសន្មតថាភាគីទាំងពីរមានបំណងថា នៅទីណាដែលមានចំណោតភ្នំ ព្រំដែនត្រូវតែស្ថិតនៅតាមបណ្តោយចំណោតភ្នំនោះឡើយ ដោយមិនគិតពីការពិចារណាដទៃទៀត។

ភាគីទាំងពីរក៏បានផ្អែកលើអំណះអំណាងដទៃទៀត ដែលមានលក្ខណៈជារូបវន្តប្រវត្តិសាស្ត្រ សាសនា និងបុរាណវិទ្យាផងដែរ ប៉ុន្តែតុលាការមិនអាចចាត់ទុកអំណះអំណាងទាំងនោះថាមានលក្ខណៈដែលត្រូវសម្រេចបានតាមផ្លូវច្បាប់ឡើយ។

*

*         *

ពាក់ព័ន្ធទៅនឹងបន្ទុកនៃភស្តុតាង ដោយផ្អែកលើជំហរជាផ្លូវការត្រូវបានបង្ហាញឱ្យឃើញថា ទោះបីជាកម្ពុជាជាដើមបណ្តឹងដែលបានចាប់ផ្តើមនីតិវិធីក៏ដោយ ក៏ប្រទេសថៃគឺជាអ្នកទាមទារសិទ្ធិរបស់ខ្លួនម្នាក់ផងដែរ ដោយសារតែការទាមទារដែលខ្លួនបានដាក់ជូននៅក្នុងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី២នៃដំណើរការនីតិវិធីតប ហើយដែលទាក់ទិននឹងអធិបតេយ្យលើដែនដីមួយកន្លែងដូចគ្នា។ ទាំងប្រទេសកម្ពុជានិងប្រទេសថៃធ្វើការទាមទាររៀងៗខ្លួន ដោយពឹងផ្អែកលើអង្គហេតុនិងការអះអាងដែលត្រូវបានបញ្ជាក់និងលើកឡើងដោយភាគីម្ខាងឬភាគីម្ខាងទៀត។ ជាការពិតណាស់ បន្ទុកនៃភស្តុតាងទាក់ទងនឹងការទាមទារ អាស្រ័យលើភាគីដែលបានអះអាងឬលើកឡើងក្នុងការទាមទារទាំងនេះ។

*

*         *

រហូតដល់ពេលដែលកម្ពុជាទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ កម្ពុជាគឺជាផ្នែកមួយនៃឥណ្ឌូចិនបារាំង ហើយទំនាក់ទំនងការបរទេសរបស់ខ្លួន ដូចគ្នានឹងប្រទេសរបស់ឥណ្ឌូចិនបារាំងមួយចំនួនផ្សេងទៀតដែរ ត្រូវបានធ្វើដោយប្រទេសបារាំង ក្នុងនាមអំណាចអាណាព្យាបាល។ ជារួម គូភាគីទាំងពីរឯកភាពទទួលស្គាល់ថា ជម្លោះបច្ចុប្បន្នមានប្រភពកំណើតមកពីការដោះស្រាយព្រំដែនក្នុងអំឡុងឆ្នាំ ១៩០៤-១៩០៨ រវាងបារាំងនិងសៀម (ដែលក្រោយមកត្រូវបានហៅថាថៃ) និងជាពិសេសថា អធិបតេយ្យលើព្រះវិហារផ្អែកលើអនុសញ្ញាព្រំដែនចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ និងផ្អែកលើព្រឹត្តិការណ៍ក្រោយពីថ្ងៃនោះមក។ ហេតុដូច្នេះហើយបានជាតុលាការមិនពិនិត្យស្ថានការណ៍ ដែលកើតមានរវាងភាគីទាំងពីរមុនអនុសញ្ញាឆ្នាំ១៩០៤នោះទេ។

បទប្បញ្ញត្តិពាក់ព័ន្ធនានានៃអនុសញ្ញាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ ដែលចែងអំពីព្រំដែននៃតំបន់ភ្នំដងរែកខាងកើតមានខ្លឹមសារដូចខាងក្រោម ៖

"**មាត្រា ១**

ព្រំដែនរវាងសៀមនិងកម្ពុជា នៅត្រើយខាងឆ្វេងទន្លេសាប ចាប់ផ្តើមពីមាត់ពាម នៃស្ទឹងរលួស រួចដើរតាមខ្សែស្របចាប់ពីចំណុចនោះឆ្ពោះទៅទិសខាងកើត រហូតដល់ជួបនឹងព្រែកកំពង់ទៀម បន្ទាប់មកបត់ឡើងទៅទិសខាងជើង ហើយខ្សែនេះប្រសព្វនឹងខ្សែបណ្តោយពីចំណុចប្រសព្វនោះរហូតដល់ជួរភ្នំដងរែក។ ចាប់ពីទីនោះមក ខ្សែព្រំដែនដើរតាមខ្សែបែងចែកទឹក ម្ខាងចន្លោះអាងទន្លេណាមសែននិងទន្លេមេគង្គ និងទន្លេណាមមូននៅម្ខាងទៀត ខ្សែនេះប្រសព្វនឹងជួរភ្នំប៉ាដាង ហើយដើរតាមកំពូលភ្នំនេះ ទៅទិសខាងកើតរហូតដល់ទន្លេមេគង្គ។ នៅខ្សែទឹកខាងលើចាប់ពីចំណុចនោះ ទន្លេមេគង្គនៅតែជាព្រំដែននៃរាជាណាចក្រសៀមស្របតាមមាត្រា១នៃសន្ធិសញ្ញាចុះថ្ងៃទី៣ ខែតុលា ឆ្នាំ១៨៩៣។"

"**មាត្រា៣**

ដំណើរការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រសៀម និងទឹកដីដែលបង្កើតបានជាឥណ្ឌូចិនបារាំង នឹងត្រូវរៀបចំធ្វើឡើង។ ការកំណត់ព្រំដែននេះនឹងត្រូវអនុវត្តដោយគណៈកម្មការចម្រុះ ដែលមានសមាសភាពមន្ត្រីតែងតាំងដោយប្រទេសជាប់កិច្ចសន្យាទាំងពីរ។ កិច្ចការទាំងនោះពាក់ព័ន្ធនឹងព្រំដែនដែលបានកំណត់ក្នុងមាត្រា១និង២ ព្រមទាំងតំបន់ដែលនៅចន្លោះទន្លេសាបនិងសមុទ្រ។"

ជាបឋម គេឃើញថាមាត្រាទាំងនេះមិនបាននិយាយអំពីប្រាសាទព្រះវិហារទេ។ ដោយហេតុផលនេះហើយ មុននឹងតុលាការអាចចេញសេចក្តីសម្រេចទាក់ទងនឹងអធិបតេយ្យភាពនៅលើតំបន់ប្រាសាទបាន លុះត្រាតែបានពិនិត្យនូវអ្វីដែលជាខ្សែព្រំដែនរួចមក។ បន្ទាប់មក ទោះបីលក្ខណៈទូទៅនៃព្រំដែនដែលកំណត់ក្នុងមាត្រា១ ជាខ្សែបែងចែកទឹកតាមជួរភ្នំដងរែក ក៏ប៉ុន្តែយោងតាមមាត្រា៣ ខ្សែព្រំដែនពិតប្រាកដនេះ នឹងត្រូវកំណត់ដោយគណៈកម្មការចម្រុះបារាំង-សៀម។ លើសពីនេះទៅទៀត ត្រូវកត់សម្គាល់ថាអ្វីដែលត្រូវកំណត់នោះគឺ "ព្រំប្រទល់" រវាងសៀមនិងឥណ្ឌូចិនបារាំង ហើយទោះបីជាការកំណត់ព្រំដែននេះជាគោល (prim facie) ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដែលចែងក្នុងមាត្រា១ក៏ដោយ ក៏គោលបំណងនៃការកំណត់ព្រំដែននេះ គឺដើម្បីបង្កើតខ្សែព្រំដែនជាក់លាក់មួយ។ ហេតុ

ដូច្នេះ ដើម្បីសម្រេចគោលដៅនេះ ខ្សែព្រំដែនគឺជាខ្សែដែលកើតចេញពីការងារនៃការកំណត់ព្រំដែន លើកលែងតែការកំណត់ព្រំដែននេះត្រូវបានបង្ហាញថាមិនមានសុពលភាព។

*

*         *

ភ្លាមៗនោះ គណៈកម្មការចម្រុះដែលមានសមាជិកបារាំង-សៀមត្រូវបានបង្កើតឡើងឱ្យទទួលបន្ទុកការងារកំណត់ព្រំដែននៅតាមស្រុកផ្សេងៗ រួមទាំងស្រុកមួយចំនួននៅផ្នែកខាងកើតជួរភ្នំដងរែក ដែលជាទីតាំងមានប្រាសាទព្រះវិហារស្ថិតនៅ។ គណៈកម្មការចម្រុះនេះមានពីរក្រុម ម្ខាងគឺបារាំងនិងម្ខាងទៀតគឺសៀម ធ្វើការរួមគ្នា ដែលមួយក្រុមមានមន្ត្រីឋានលេខា និងមន្ត្រីរដ្ឋបាលជនជាតិបារាំង ក្រោមការដឹកនាំរបស់ប្រធានជាជនជាតិបារាំង ហើយមួយក្រុមទៀតគឺសមាជិកសៀមក្រោមការដឹកនាំរបស់ប្រធានជាជនជាតិសៀម។ ពាក់ព័ន្ធនឹងព្រំដែននៅជួរភ្នំដងរែក ការងាររបស់គណៈកម្មការចម្រុះនេះត្រូវបានកម្រិតឱ្យធ្វើតែនៅភាគខាងកើត (ម្តុំខាងកើតច្រកកិល) ដែលមានប្រាសាទព្រះវិហារតាំងនៅប៉ុណ្ណោះ។ នៅពេលនេះ ភាគខាងលិចនៃជួរភ្នំដងរែកទាំងមូលស្ថិតនៅក្នុងប្រទេសថៃ។ ដោយសារតែនៅពេលមានដំណោះស្រាយព្រំដែនបន្ថែមតាមសន្ធិសញ្ញាចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ប៉ុណ្ណោះ ទើបស្រុកមួយចំនួនជាប់នឹងភាគខាងលិចភ្នំដងរែកត្រូវបានដាក់ក្នុងប្រទេសកម្ពុជា ដែលក្រោយមកតំបន់នេះបានក្លាយជាតំបន់ព្រំដែន។ កិច្ចការកំណត់ព្រំដែននៅក្នុងតំបន់ព្រំដែនចុងក្រោយនេះ ត្រូវបានប្រគល់ទៅឱ្យគណៈកម្មការចម្រុះទី២ ដែលត្រូវបានបង្កើតឡើងតាមសន្ធិសញ្ញាឆ្នាំ១៩០៧។

គណៈកម្មការចម្រុះដែលត្រូវបានបង្កើតឡើងតាមអនុសញ្ញាឆ្នាំ១៩០៤ បានរៀបចំកិច្ចប្រជុំលើកទី១របស់ខ្លួន នៅខែមករា ឆ្នាំ១៩០៥ ប៉ុន្តែកិច្ចប្រជុំនោះមិនបានសម្រេចផ្នែកនៃកិច្ចប្រតិបត្តិការរបស់ខ្លួន ដែលពាក់ព័ន្ធនឹងព្រំដែននៅតាមភាគខាងកើតនៃជួរភ្នំដងរែកទេ រហូតដល់ខែធ្នូ ឆ្នាំ១៩០៦ បើទោះបីជាមាននៅក្នុងកំណត់ហេតុរបស់គណៈកម្មការ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩០៦ ថាសមាជិកជនជាតិបារាំងមួយរូបនៃគណៈកម្មការនេះគឺអនុសេនីយ៍ឯក Tixier បានធ្វើដំណើរឆ្លងកាត់ភ្នំដងរែក នៅខែកុម្ភៈ ឆ្នាំ១៩០៥ ក៏ដោយ។

កិច្ចប្រជុំថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩០៦ ដែលបានប្រព្រឹត្តទៅនៅអង្គរវត្តបានព្រមព្រៀងថា គណៈកម្មការនេះគួរតែឡើងភ្នំដងរែកពីវាលទំនាបខាងប្រទេសកម្ពុជា ដោយឆ្លងកាត់ច្រកកិលដែលស្ថិតនៅទិសខាងលិចនៃប្រាសាទព្រះវិហារ ហើយធ្វើដំណើរឆ្ពោះទៅទិសខាងកើតតាមបណ្តោយជួរភ្នំនេះតាមផ្លូវដដែល (ឬតាមខ្សែបន្ទាត់ដដែល) ដែលអនុសេនីយ៍ឯក Tixier បានដើរឆ្លងកាត់នៅឆ្នាំ១៩០៥។ កំណត់ហេតុប្រជុំខាងលើបានបញ្ជាក់ថា រាល់ការចុះពិនិត្យភូមិសាស្រ្តចាំបាច់ទាំងអស់នៅចន្លោះផ្លូវនេះនិងជួរកំពូលភ្នំ (ដែលផ្លូវនេះដើរស្ទើរតែស្របគ្នានឹងជួរកំពូលភ្នំ) អាចយកវិធីនេះមកប្រើប្រាស់បាន ដោយហេតុថា ផ្លូវនេះមានចម្ងាយយ៉ាងឆ្ងាយបំផុតតែពី ១០ ទៅ ១៥ គីឡូម៉ែត្រប៉ុណ្ណោះពីកំពូលភ្នំនៅខាងភាគីសៀម។ ពុំមានការជំទាស់ទេថា ប្រធានក្រុមបារាំង និងប្រធានក្រុមសៀមនៃគណៈកម្មការចម្រុះ ដែលជាតំណាងឱ្យគណៈកម្មការនេះ ពិតជាបានធ្វើដំណើរតាមផ្លូវនេះ និងថានៅក្នុងពេលធ្វើដំណើរនោះ ពួកគេបានទស្សនាប្រាសាទព្រះវិហារ។ ប៉ុន្តែពុំមានកំណត់ត្រាអំពីសេចក្តីសម្រេចណាមួយដែលថាពួកគេអាចបានធ្វើនោះទេ។

នៅក្នុងកិច្ចប្រជុំនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩០៦ដដែលនេះ ក៏បានព្រមព្រៀងផងដែរថាសមាជិកម្នាក់ទៀតនៃក្រុមបារាំងរបស់គណៈកម្មការ គឺអនុសេនីយ៍ឯក អ៊ុំ ត្រូវវាស់វែងផ្នែកខាងកើតទាំងមូលនៃជួរភ្នំដងរែក ដែលមានប្រាសាទព្រះវិហារតាំងនៅ ដោយចាប់ផ្តើមពីចុងខាងកើត និងថាគាត់ត្រូវចាកចេញទៅបំពេញការងារនេះនៅថ្ងៃបន្ទាប់។

ដូច្នេះបានបញ្ជាក់យ៉ាងច្បាស់ថា គណៈកម្មការចម្រុះនេះពិតជាមានឆន្ទៈពិតប្រាកដក្នុងការកំណត់ព្រំដែនក្នុងតំបន់ដងរែក និងថាគណៈកម្មការចម្រុះនេះបានចាត់វិធានការចាំបាច់គ្រប់បែបយ៉ាង ដើម្បីដំណើរការការងារកំណត់ព្រំដែន។ តាមពិត ការងារនេះត្រូវបានបញ្ចប់ហើយ ដោយហេតុថានៅចុងខែមករា ឆ្នាំ១៩០៧ ឯកអគ្គរដ្ឋទូតបារាំងប្រចាំក្រុងបាងកកបានរាយការណ៍ជូនរដ្ឋមន្រ្តីការបរទេសនៅប៉ារីសថា គាត់បានទទួលដំណឹងជាផ្លូវការពីប្រធានក្រុមបារាំងនៃគណៈកម្មការចម្រុះថា ការងារកំណត់ព្រំដែនទាំងមូលត្រូវបានបញ្ចប់ដោយគ្មានឧបទ្ទវហេតុអ្វីឡើយ ហើយថាខ្សែព្រំដែនត្រូវបានកំណត់ជាស្ថាពររួចរាល់ហើយ លើកលែងតែនៅក្នុងតំបន់សៀមរាបប៉ុណ្ណោះ។ លើសពីនេះទៀត នៅក្នុងរបាយការណ៍ស្តីពីកិច្ចការនៃការកំណត់ព្រំដែនទាំងមូល ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩០៧

ផ្ញើជូនរដ្ឋាភិបាលរបស់ខ្លួន ប្រធានក្រុមបារាំងបាននិយាយថា "តាមបណ្តោយភ្នំដងរែកទាំងមូលនិងរហូតដល់ទន្លេមេគង្គ ការកំណត់ព្រំដែនមិនអាចបង្កឱ្យមានការលំបាកណាមួយទេ"។ របាយការណ៍បានលើកឡើងផងដែរអំពីផែនទីដែលផលិតដោយប្រទេសថៃដែលត្រូវបានរៀបចំដោយអគ្គនាយកដ្ឋានភូមិសាស្ត្រភូមិន្ទថៃ នៅទីក្រុងបាងកកនៅពេលថ្មីៗនេះ ដែលបានគូស "ផ្លូវដែលគណៈកម្មការចម្រុះឆ្នាំ១៩០៤ ដើរតាម" នៅភ្នំដងរែក។

ហេតុដូច្នេះហើយ វាហាក់ដូចជាច្បាស់ណាស់ថាព្រំដែនត្រូវបានវាស់វែង និងកំណត់រួចហើយ ប៉ុន្តែសំណួរគឺថាតើអ្វីជាខ្សែព្រំដែននោះ? (ជាពិសេសនៅតំបន់ព្រះវិហារ) នរណាជាអ្នកកំណត់? ដោយវិធីណា? ហើយតាមបញ្ជារបស់នរណា? ការលំបាកក្នុងការឆ្លើយសំណួរទាំងនេះគឺស្ថិតនៅត្រង់ថា បន្ទាប់ពីមានកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មការទី១ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩០៦ គេមិនឃើញមានការយោងបន្ថែមទាល់តែសោះនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រោយៗមកទៀត ស្តីពីបញ្ហាព្រំដែននៅក្នុងតំបន់ភ្នំដងរែកនេះទេ។

គេបានដឹងថានៅពេលនោះ គណៈកម្មការបានបញ្ចប់កិច្ចការរបស់ខ្លួនសឹងតែអស់ទៅហើយនៅលើដីជាក់ស្តែង ហើយគេកំពុងរង់ចាំរបាយការណ៍ និងផែនទីបណ្តោះអាសន្នរបស់មន្ត្រីឋានលេខាសាស្ត្រ (អនុសេនីយ៍ឯក អ៊ុំ និងអ្នកផ្សេងទៀត)។ របាយការណ៍និងផែនទីទាំងនេះមិនទាន់បានធ្វើរួចរាល់ហើយទេរហូតដល់ខែកុម្ភៈ-មីនា ឆ្នាំ១៩០៧ ដែលតាមធម្មតាពេលវេលានេះ គណៈកម្មការនឹងត្រូវជួបប្រជុំគ្នាម្តងទៀតដើម្បីពិនិត្យពិចារណាលើរបាយការណ៍និងផែនទីទាំងនេះ។ គេបានដឹងថា មានកិច្ចប្រជុំមួយត្រូវបានកំណត់ជាបណ្តោះអាសន្នធ្វើនៅថ្ងៃទី៨ ខែមីនា។ នេះពិតជាចេតនាក្នុងការកោះប្រជុំដែលអាចឃើញតាមរយៈលិខិតកោះប្រជុំបន្ទាន់ពីឯកអគ្គរដ្ឋទូតបារាំងប្រចាំក្រុងបាងកក ផ្ញើជូនរដ្ឋមន្ត្រីការបរទេសបារាំងនៅទីក្រុងប៉ារីស ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩០៧ ដោយមានអមនូវរបាយការណ៍របស់លោកវរសេនីយ៍ឯក Bernard ប្រធានក្រុមបារាំងនៃគណៈកម្មការ។ នៅក្នុងលិខិតនោះដែរ លោកឯកអគ្គរដ្ឋទូត បានលើកឡើងថា "ផែនទីដែលបង្ហាញឱ្យឃើញនូវព្រំដែនអាចត្រូវបានធ្វើបច្ចុប្បន្នកម្មក្នុងរយៈពេលដ៏ខ្លីសមរម្យ ហើយកិច្ចប្រជុំពេញអង្គរបស់សមាជិកគណៈកម្មការបារាំងនិងសៀម ប្រហែលជានឹងអាចរៀបចំធ្វើនៅមុនថ្ងៃទី១៥

ខែមីនា"។ ប៉ុន្តែជាក់ស្តែង ពុំមានកិច្ចប្រជុំណាមួយត្រូវបានប្រារព្ធឡើងនោះទេ។ ក្នុងពេលជាមួយគ្នានោះដែរ រដ្ឋាភិបាលទាំងពីរបានដំណើរការចរចាលើសន្ធិសញ្ញាព្រំដែនថ្មីមួយទៀត។ សន្ធិសញ្ញានេះដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ បានចែងអំពីការដោះដូរទឹកដី និងបទប្បញ្ញត្តិច្បាស់លាស់ទាក់ទងនឹងព្រំដែនទាំងអស់ដែលមិនបានចែងនៅក្នុងដំណោះស្រាយនៃសន្ធិសញ្ញាឆ្នាំ១៩០៤មុន។

ដូច្នេះ គណៈកម្មការចម្រុះកំណត់ព្រំដែនទី២ត្រូវបានបង្កើតឡើងតាមសន្ធិសញ្ញាឆ្នាំ១៩០៧។ ដូចដែលបានលើកឡើងពីខាងដើម កិច្ចការមួយចំនួនរបស់គណៈកម្មការនេះគឺ កំណត់ផ្នែកនៃតំបន់ភ្នំដងរែកដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការទី១ និយាយឱ្យចំចាប់ពីច្រកកិលទៅទិសខាងលិច ដូច្នេះហើយមិនរួមបញ្ចូលតំបន់ព្រះវិហារដែលស្ថិតនៅទិសខាងកើតនៃច្រកនោះទេ។ តាមពិតមានការងារជាន់គ្នាខ្លះៗរវាងគណៈកម្មការទាំងពីរនៅក្នុងតំបន់កិល ប៉ុន្តែការងារជាន់គ្នានេះមិនលាតសន្ធឹងដល់តំបន់ព្រះវិហារនោះទេ។ ទោះជាយ៉ាងណាក្តី នៅឬនៅក្បែរច្រកកិលមានភស្តុតាងនៅក្នុងកំណត់ត្រារបស់គណៈកម្មការទី២ ដែលថាខ្សែព្រំដែនដែលគូសដោយគណៈកម្មការនេះ បានភ្ជាប់ជាមួយខ្សែព្រំដែនដែលមានស្រាប់ ដែលតម្រង់ឆ្ពោះទៅខាងកើតរហូតដល់តំបន់ប្រាសាទ និងហួសតំបន់ប្រាសាទនេះទៅទៀត។ គេពុំមានព័ត៌មានជាក់លាក់ថាតើខ្សែព្រំដែននេះជាអ្វីនោះទេ ឬថាតើខ្សែព្រំដែននេះត្រូវបានបង្កើតឡើងដោយរបៀបណាទេ ប៉ុន្តែមានការសន្មតមួយមានទម្ងន់រឹងមាំនៅគ្រប់កាលៈទេសៈ ដែលថាទោះតាមរបៀបណាក៏ដោយខ្សែព្រំដែននេះ គឺជាលទ្ធផលនៃការងារវាស់វែងរបស់គណៈកម្មការទី១ និងដែលប្រធានក្រុមបារាំងសរសេរក្នុងរបាយការណ៍ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩០៧ ដោយបានបញ្ជាក់ថាការងារវាស់វែងនេះត្រូវបានបញ្ចប់រួចរាល់ដោយមិនជួបការលំបាកទាល់តែសោះ។ តាមមាត្រា៤នៃសន្ធិសញ្ញាឆ្នាំ១៩០៧ តុលាការកត់សំគាល់ឃើញថា ទោះបីជាគណៈកម្មការចម្រុះទី២មានភារកិច្ចកំណត់ "ព្រំដែនថ្មី" តាមសន្ធិសញ្ញានោះក៏ដោយ តាមប្រការ III នៃពិធីសារដែលភ្ជាប់ជាមួយសន្ធិសញ្ញាគណៈកម្មការនេះ ក៏មានភារកិច្ចកំណត់ព្រំដែននៅផ្នែកទាំងអស់នៃព្រំដែនដូចមានចែងក្នុងប្រការ I នៃពិធីសារនេះ។ បទប្បញ្ញត្តិចុងក្រោយនេះទាក់ទងនឹងជួរភ្នំដងរែកទាំងមូល ចាប់ពីចំណុចមួយនៅពាក់កណ្តាលភាគខាងលិចនៃជួរភ្នំនេះបន្តដល់ជួរភ្នំប៉ាដាងនៅភាគខាងកើតនៃភ្នំដងរែករួចបន្តរហូតដល់ទន្លេមេគង្គ។

ដូច្នេះ ប្រសិនបើភាគខាងកើតនៃភ្នំដងរែកនិងតំបន់ភ្នំប៉ាដាង មិនទាន់ត្រូវបានកំណត់ព្រំដែនដោយគណៈកម្មការចម្រុះទី១ (ឆ្នាំ១៩០៤) នោះគណៈកម្មការទី២ (ឆ្នាំ១៩០៧) មានភារកិច្ចធ្វើការងារនេះ។ ក្រៅពីការងារជាន់គ្នាដែលបានលើកឡើងខាងលើ (ដោយមិនលាតសន្ធឹងដល់ព្រះវិហារ) គណៈកម្មការនេះមិនបានធ្វើកិច្ចការនេះទេ ហេតុដូច្នេះហើយការសន្និត គឺថាការងារវាស់វែងនេះត្រូវបានធ្វើរួចរាល់ហើយ។

ជាក់ស្តែង គណៈកម្មការចម្រុះទី១មិនបានរៀបចំកិច្ចប្រជុំជាផ្លូវការណាមួយឡើយក្រោយថ្ងៃទី១៩ ខែមករា ឆ្នាំ១៩០៧។ គេមិនត្រូវភ្លេចទេថា នៅពេលដែលកិច្ចប្រជុំបែបនេះគួរតែត្រូវបានគេរៀបចំធ្វើឡើង ក្នុងគោលបំណងបញ្ចប់កិច្ចការរបស់គណៈកម្មការការចាប់អារម្មណ៍នៅក្នុងប្រទេសទាំងពីរ និងពីសំណាក់បុគ្គលដែលបានទទួលសិទ្ធិពិសេសដើម្បីបំពេញកិច្ចការនិងបញ្ចេញមតិក្នុងនាមពួកគេលើកិច្ចការទាំងនេះ គឺផ្តោតលើការសម្រេចបាននូវសន្ធិសញ្ញាចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧។ ការកង្វល់ជាចម្បងរបស់ពួកគេ ជាពិសេសរបស់លោកវរសេនីយ៍ឯក Bernard មិនមែនការមិនបានបញ្ចប់ជាពិធីការនូវលទ្ធផលនៃការកំណត់ព្រំដែន ដែលពួកគេត្រូវបំពេញកន្លងមកទេ។

ដំណាក់កាលចុងក្រោយនៃប្រតិបត្តិការកំណត់ព្រំដែន គឺជាការរៀបចំនិងបោះពុម្ពផ្សាយផែនទី។ ចំពោះការអនុវត្តការងារបច្ចេកទេសនេះ រដ្ឋាភិបាលសៀមដែលនៅពេលនោះពុំមានមធ្យោបាយគ្រប់គ្រាន់ បានស្នើជាផ្លូវការឱ្យមន្ត្រីឋានលេខាបារាំងគូសផែនទីក្នុងតំបន់ព្រំដែននេះ។ វាក្យខណ្ឌទីមួយនៃកំណត់ហេតុរបស់កិច្ចប្រជុំគណៈកម្មការចម្រុះទី១ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩០៥ បានបញ្ជាក់យ៉ាងច្បាស់ថា សំណើនេះបានទទួលការឯកភាពពីក្រុមសៀមនៃគណៈកម្មការនេះ ដែលអាចជាអ្នកផ្តួចផ្តើមគំនិតទៀតផងដោយហេតុថានៅក្នុងលិខិតមួយ ចុះនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩០៨ ដែលនៅក្នុងលិខិតនេះឯកអគ្គរដ្ឋទូតសៀមនៅទីក្រុងប៉ារីសបានផ្ញើជូនទៅរដ្ឋាភិបាលរបស់ខ្លួន អំពីផែនទីដែលជាលទ្ធផលចុងក្រោយនៃការគូសផែនទី លោកទូតសៀមរូបនេះបានយោងលើ "គណៈកម្មការចម្រុះកំណត់ព្រំដែន និងសំណើរបស់គណៈកម្មការសៀមដែលស្នើឱ្យគណៈកម្មការបារាំងជាអ្នករៀបចំផែនទីព្រំដែនផ្សេងៗ" ទៀតផង។ ការណ៍នេះគឺជានយោបាយច្បាស់លាស់របស់អាជ្ញាធរសៀម ដែលត្រូវបានបញ្ជាក់សាជាថ្មីនៅក្នុងគណៈកម្មការ

ចម្រុះទី២ (ឆ្នាំ១៩០៧) ដែលថា សហាសេរិកសៀមបានស្នើសុំដល់សមាជិកបារាំងនៃគណៈកម្មការនេះឱ្យអនុវត្តការគូសផែនទីភូមិសាស្ត្រនេះ ដូចដែលមាននៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩០៨។

រដ្ឋាភិបាលបារាំងបានចាត់វិធានការចាំបាច់ ដើម្បីឱ្យកិច្ចការនេះត្រូវអនុវត្តបានដោយមន្ត្រីយោធាបារាំងមួយក្រុមមានគ្នា៤នាក់ដែលក្នុងនោះ៣នាក់ គឺលោកអនុសេនីយ៍ឯក Tixier, Kerler និង De Batz ធ្លាប់ជាសមាជិករបស់គណៈកម្មការចម្រុះទី១។ ក្រុមនេះបានធ្វើការក្រោមការដឹកនាំទូទៅរបស់វរសេនីយ៍ឯក Bernard ហើយនៅចុងសរទរដូវ ឆ្នាំ១៩០៧ ក្រុមនេះបានបញ្ចប់ផែនទីមួយស៊េរីដែលមានចំនួន១១ផ្ទាំង គ្របដណ្តប់មួយភាគធំនៃព្រំដែនរវាងសៀមនិងឥណ្ឌូចិនបារាំង រួមបញ្ចូលទាំងផ្នែកទាំងឡាយដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ។ ផែនទីទាំងនេះត្រូវបានបោះពុម្ព និងផ្សព្វផ្សាយដោយក្រុមហ៊ុនគូសផែនទីដ៏ល្បីល្បាញរបស់បារាំងមួយដែលមានឈ្មោះថា H. Barrère។

ផែនទីទាំង១១ផ្ទាំងនេះត្រូវបញ្ជូនទៅឱ្យរដ្ឋាភិបាលសៀម ទៅតាមនីតិវិធីត្រឹមត្រូវជាផែនទីដែលរដ្ឋាភិបាលសៀមបានស្នើសុំ ហើយតុលាការនឹងពិចារណាអំពីកាលៈទេសៈនៃការបញ្ជូនផែនទី និងការសន្និដ្ឋានផ្អែកលើការប្រាស្រ័យទាក់ទងគ្នានេះនៅពេលក្រោយ។ ផែនទី៣ផ្ទាំងក្នុងចំណោមផែនទីទាំងអស់ត្រូវលែងប្រើការកើតដោយព្រឹត្តិការណ៍ ព្រោះថាតំបន់ព្រំដែនចាស់ដែលផែនទីទាំងនេះបានបង្ហាញ ឥឡូវនេះបានស្ថិតនៅក្នុងទឹកដីរបស់កម្ពុជាទាំងស្រុងយោងតាមសន្ធិសញ្ញា ខែមីនា ឆ្នាំ១៩០៧។ អាស្រ័យហេតុនេះ សៀមមិនត្រូវបានស្នើសុំឱ្យទទួលយកឬបដិសេធផែនទីទាំងនេះឡើយ។ ប៉ុន្តែផែនទីផ្សេងទៀតនៅតែមានប្រយោជន៍ដែលសម្រាប់ប្រទេសសៀម។ ក្នុងចំណោមផែនទីទាំងនេះ មានផែនទីមួយជាផ្នែកនៃជួរភ្នំដងរែក ដែលមានប្រាសាទព្រះវិហារតាំងនៅ ហើយនៅលើផែនទីនោះគេបានគូសខ្សែព្រំដែនដែលអះអាងថា ជាលទ្ធផលនៃការងារកំណត់ព្រំដែន និងដែលបានដាក់ពយភ្នំព្រះវិហារទាំងមូល ព្រមទាំងតំបន់ប្រាសាទទៀតផងស្ថិតនៅក្នុងទឹកដីកម្ពុជា។ ដូច្នេះប្រសិនបើការកំណត់ព្រំដែន ដែលត្រូវបានធ្វើឡើងនៅភាគខាងកើតនៃជួរភ្នំដងរែកបានកំណត់ឬមានបំណងកំណត់តាមខ្សែបែងចែកទឹក នោះផែនទីនេះអាចចាត់ទុកថាបានបង្ហាញខ្សែបែងចែកទឹកបែបនេះហើយ។ ផែនទីនេះ ត្រូវបានរៀបចំឡើងដោយប្រទេស

កម្ពុជានៅក្នុងឧបសម្ព័ន្ធ១នៃដំណើរការនីតិវិធីរបស់ខ្លួន ហើយត្រូវបានគេដឹងនៅក្នុងរឿងក្តីនេះថាជាផែនទីឧបសម្ព័ន្ធ ១ (នឹងត្រូវយោងនៅក្នុងសាលដីកានេះ)។

ផែនទីនេះហើយដែលកម្ពុជាយកធ្វើជាមូលដ្ឋានចម្បង ដើម្បីគាំទ្រដល់ការទាមទារអធិបតេយ្យរបស់ខ្លួនលើប្រាសាទនេះ។ ផ្ទុយទៅវិញ ប្រទេសថៃតវ៉ាចំពោះការទាមទារណាមួយ ដែលផ្អែកលើផែនទីនេះ ដោយមានសំអាងហេតុដូចតទៅ៖ ទីមួយ ផែនទីនេះមិនមែនបានមកពីការងាររបស់គណៈកម្មការចម្រុះទេ ហេតុដូច្នេះហើយទើបផែនទីនេះពុំមានលក្ខណៈចាប់បង្ខំ។ ទីពីរ នៅត្រង់តំបន់ព្រះវិហារ ផែនទីនេះ មានកំហុសផ្នែកសំភារៈដែលមិនអាចពន្យល់បាន ដោយផ្អែកលើការអនុវត្តនូវអំណាចឆន្ទានុសិទ្ធិក្នុងការកែប្រែដែលគណៈកម្មការអាចមាន។ យោងតាមការតវ៉ារបស់ថៃ កំហុសនោះគឺថាខ្សែព្រំដែនដែលត្រូវបានបង្ហាញលើផែនទីនេះ មិនមែនជាខ្សែបែងចែកទឹកពិតប្រាកដក្នុងតំបន់នេះទេ ហើយថាប្រសិនបើវាជាខ្សែបន្ទាត់ដែលគូសតាមខ្សែបែងចែកទឹកពិតប្រាកដនោះ តំបន់ប្រាសាទនេះនឹងស្ថិតក្នុងទឹកដីថៃ។ ថៃបានតវ៉ាបន្ថែមទៀតថា បើនិយាយអំពីតំបន់ព្រះវិហារខ្លួនមិនដែលទទួលយកផែនទីនេះឬខ្សែព្រំដែនដែលបានបង្ហាញនៅលើផែនទីនេះ យ៉ាងហោចណាស់ទាក់ទងទៅនឹងព្រះវិហារ ដែលការទទួលស្គាល់នេះតម្រូវឱ្យខ្លួនត្រូវអនុវត្តតាមនោះទេ។ ម៉្យាងវិញទៀត ប្រសិនបើថៃពិតជាបានទទួលយកផែនទីនេះ គឺថៃធ្វើដូច្នេះក៏ដោយសារតែខ្លួនមានជំនឿដោយមានការភ័ន្តច្រឡំថា ខ្សែព្រំដែនលើផែនទីនេះត្រូវបានគេគូសត្រឹមត្រូវទៅតាមខ្សែបែងចែកទឹក។

នៅពេលនេះ តុលាការនឹងពិចារណាតែទៅលើការតវ៉ាទី១ប៉ុណ្ណោះ ដោយផ្អែកលើទឡ្ហីករណ៍ដែលតុលាការយល់ឃើញថាត្រឹមត្រូវ ពោលគឺផែនទីនេះមិនធ្លាប់ដែលបានទទួលការឯកភាពជាផ្លូវការពីគណៈកម្មការចម្រុះទី១ទេ ដោយហេតុថាគណៈកម្មការនេះលែងដំណើរការតាំងពីប៉ុន្មានខែមុនពេលផលិតបានផែនទីនេះម្ល៉េះ។ កំណត់ត្រាមិនបានបង្ហាញថា តើផែនទីនិងខ្សែបន្ទាត់នេះបានផ្អែកតាមសេចក្តីសម្រេចឬការណែនាំណាមួយពីគណៈកម្មការដល់មន្ត្រីឋានលេខា នៅពេលគណៈកម្មការកំពុងមានដំណើរការនោះទេ។ អ្វីដែលច្បាស់នោះគឺថា ផែនទីនេះប្រាកដជាបានផ្អែកលើមូលដ្ឋានណាមួយហើយ ហើយតុលាការយល់ដោយពុំមានវិមតិសង្ស័យឡើយថា ផែនទីនេះបានផ្អែកទៅលើការងាររបស់

មន្ត្រីឋានលេខានៅតំបន់ភ្នំដងរែក។ ដោយផែនទីនេះ ជាផែនទីមួយក្នុងចំណោមស៊េរីផែនទីនៃតំបន់ព្រំដែនដែលបានផលិតដោយអ្នកជំនាញឋានលេខាសាស្ត្ររបស់រដ្ឋាភិបាលបារាំងតាមសំណើរបស់អាជ្ញាធរសៀម ដែលត្រូវបានបោះពុម្ពនិងផ្សព្វផ្សាយដោយក្រុមហ៊ុនល្បីឈ្មោះមួយនៅប៉ារីស គ្រប់ចំណុចទាំងអស់ត្រូវបានបង្ហាញយ៉ាងច្បាស់នៅលើផែនទីនេះ ហេតុដូច្នេះហើយ ផែនទីនេះមានលក្ខណៈផ្លូវការ ហើយផែនទីនេះមានអំណាចរបស់ខ្លួនតាមលក្ខណៈបច្ចេកទេស ហើយផែនទីនេះមានប្រភពកំណើតប្រកបដោយលក្ខណៈច្បាស់ទែងឥតឱ្យមន្ទិលសង្ស័យ។ ទោះជាយ៉ាងណាក៏ដោយ តុលាការសន្និដ្ឋានថា នៅពេលចាប់ផ្តើម និងនៅពេលផលិតផែនទីនេះពុំមានលក្ខណៈតម្រូវឱ្យគូភាគីអនុវត្តតាមទេ។

*

* *

ថៃបានបង្ហាញហេតុផលថា ដោយសារពុំមានការកំណត់ព្រំដែនណាមួយដែលបានយល់ព្រម និងអនុម័តដោយគណៈកម្មការចម្រុះឬដោយផ្អែកលើការណែនាំរបស់ខ្លួនតាមស្មារតីនៃមាត្រា១នៃអនុសញ្ញាឆ្នាំ១៩០៤ ខ្សែព្រំដែនចាំបាច់ត្រូវតែអនុវត្តដោយម៉ឺងម៉ាត់តាមខ្សែបែងចែកទឹកពិតប្រាកដ ហើយថានៅតំបន់ព្រះវិហារខ្សែបន្ទាត់នេះនឹងដាក់ប្រាសាទព្រះវិហារនៅក្នុងទឹកដីថៃ។ បើទុកជាទទួលស្គាល់ថា គណៈកម្មការចម្រុះមានឆន្ទានុសិទ្ធិមួយចំនួនក្នុងការងាកចេញពីខ្សែបែងចែកទឹក ដើម្បីជៀសវាងភាពមិនប្រក្រតី និងមានឆន្ទានុសិទ្ធិពិនិត្យលើហេតុការណ៍នៅតាមតំបន់ជាក់ស្តែងសុទ្ធសាធនោះ ក៏ថៃជំទាស់ថា ការងាកចេញណាមួយ ដូចជាការដាក់ប្រាសាទព្រះវិហារនៅក្នុងទឹកដីកម្ពុជា នឹងធ្វើឱ្យលើសវិសាលភាពនៃអំណាចឆន្ទានុសិទ្ធិដែលគណៈកម្មការចម្រុះមាន ដោយមិនបានពិភាក្សាច្បាស់លាស់ជាមួយរដ្ឋាភិបាលទាំងពីរ។

បើទុកជាខ្លឹមសារនៃការជំទាស់អាចមានដោយការលើកឡើងដោយខ្លួនឯងនេះក្តី តុលាការយល់ឃើញថា ការជំទាស់នេះមិនចំបញ្ហាជាក់ស្តែងពាក់ព័ន្ធនៅទីនេះទេ។ បើទុកជាពុំមានការកំណត់ព្រំដែននៅប៉ែកខាងកើតនៃភ្នំដងរែក ដែលបានយល់ព្រមនិងអនុម័តដោយគណៈកម្មការចម្រុះក៏ដោយ ក៏ជាក់ស្តែងបានបើកផ្លូវឱ្យរដ្ឋាភិបាលទាំងពីរទទួលយកនូវការកំណត់ព្រំដែននៅតំបន់នោះបាន ដោយប្រើប្រាស់ការងាររបស់សមាជិកបច្ចេកទេស

នៃគណៈកម្មការចម្រុះ។ ចំពោះការកំណត់ព្រំដែនណាមួយដែលងាកចេញពីខ្សែបែងចែកទឹក បើផ្អែកតាមការតវ៉ារបស់ថៃ ដោយហេតុថាការកំណត់ព្រំដែនដែលបានចង្អុលបង្ហាញនៅលើផែនទីឧបសម្ព័ន្ធ១ មិនមែនជាការកំណត់ព្រំដែនរបស់គណៈកម្មការចម្រុះនោះពុំមានហេតុផលអ្វីដែលត្រូវពិភាក្សាថា តើការងាកចេញដែលអាចកើតមាននៅតំបន់ព្រះវិហារស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់គណៈកម្មការចម្រុះនោះឬក៏អត់ទេ។ ហេតុផលនៅត្រង់ថា តាមពិតវាត្រូវស្ថិតក្នុងអំណាចរបស់រដ្ឋាភិបាលទាំង២ ដើម្បីសម្រេចអំពីការងាកចេញបែបនេះ។

ហេតុដូច្នេះហើយ បញ្ហាពិតប្រាកដដែលជាបញ្ហាសំខាន់មួយនៅក្នុងរឿងក្ដីនេះគឺថា តើភាគីទាំងពីរពិតជាបានទទួលស្គាល់ផែនទីឧបសម្ព័ន្ធ១ដែរឬទេ? ហើយថាតើខ្សែបន្ទាត់ដែលចង្អុលបង្ហាញនៅលើផែនទីនេះ ជាលទ្ធផលនៃការងារកំណត់ព្រំដែននៅក្នុងតំបន់ព្រះវិហារ ដែលនាំឱ្យផែនទីនេះមានលក្ខណៈតម្រូវឱ្យអនុវត្តតាមដោយខានមិនបានដែរឬទេ?

ចំពោះបញ្ហានេះ ថៃបដិសេធដោយអះអាងថាខ្លួនប្រកាន់យកឥរិយាបថអកម្មប៉ុណ្ណោះចំពោះអ្វីដែលកើតឡើងក្រោយមកទៀត។ ថៃក៏អះអាងផងដែរថា សកម្មភាពដែលពាក់ព័ន្ធច្រើនទៅនឹងការខកខានមិនបានជំទាស់ មិនគ្រប់គ្រាន់ថាខ្លួនជាភាគីបានយល់ព្រមទៅលើការងាកចេញនៅព្រះវិហារ ពីខ្សែបែងចែកទឹកដែលមានចែងនៅក្នុងមាត្រា១នៃអនុសញ្ញាឆ្នាំ១៩០៤ រហូតដល់ថ្នាក់ធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យលើតំបន់ប្រាសាទនោះទេ។

តុលាការយល់ឃើញផ្សេងចំពោះបញ្ហានេះ។ តាមកំណត់ហេតុបង្ហាញច្បាស់ថាការបោះពុម្ពផ្សាយនិងការបញ្ជូនផែនទីទាំង១១ផ្ទាំង ដែលបានលើកឡើងខាងលើរួមទាំងផែនទីឧបសម្ព័ន្ធ១ផង គឺជាព្រឹត្តិការណ៍សំខាន់មួយ។ នេះមិនមែនគ្រាន់តែជាការដោះដូរគ្នារវាងរដ្ឋាភិបាលបារាំងនិងសៀមនោះទេ តែបើដូច្នោះមែននោះវាអាចមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់។ ផ្ទុយទៅវិញ ផែនទីទាំងអស់ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅដល់គ្រប់មជ្ឈដ្ឋានបច្ចេកទេសពាក់ព័ន្ធទាំងអស់ ព្រមទាំងបានជូនដំណឹងដល់ស្ថាប័នភូមិសាស្ត្រឈានមុខនៅក្នុងប្រទេសសំខាន់ៗ និងទៅដល់មជ្ឈដ្ឋានដទៃទៀតក្នុងតំបន់ដែលមានការពាក់ព័ន្ធនឹងស្ថានបេសកកម្មការទូតសៀមអមរដ្ឋាភិបាលអង់គ្លេស អាឡឺម៉ង់

រុស្ស៊ី និងអាមេរិក និងទៅដល់គ្រប់សមាជិកទាំងអស់នៃគណៈកម្មការចម្រុះបារាំង-សៀម ផងដែរ។ ការចែកចាយដើមដំបូងមានចំនួន១៦០ច្បាប់ ដែលមួយច្បាប់ៗមាន១១ផ្ទាំង។ ផែនទី៥០ ត្រូវបានចែកទៅឱ្យរដ្ឋាភិបាលសៀម។ ការដែលផែនទីឧបសម្ព័ន្ធ១ត្រូវបាន ចែកជូនដើម្បីជាការបង្ហាញពីលទ្ធផលនៃការងារកំណត់ព្រំដែន គឺបង្ហាញច្បាស់នៅក្នុង លិខិតចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩០៨ របស់អគ្គរាជទូតថៃនៅទីក្រុងប៉ារីស ផ្ញើជូន រដ្ឋមន្ត្រីការបរទេសនៅទីក្រុងបាងកក ដែលក្នុងលិខិតនោះលោកបានមានប្រសាសន៍ថា "ទាក់ទងនឹងសំណើរបស់គណៈកម្មការចម្រុះកំណត់ព្រំដែន និងសមាជិកគណៈកម្មការ សៀម ដែលសុំឱ្យសមាជិកគណៈកម្មការបារាំងរៀបចំផែនទីព្រំដែនផ្សេងៗ ឥឡូវនេះ សមាជិកគណៈកម្មការបារាំងបានរៀបចំការងាររបស់ខ្លួនចប់រួចរាល់ហើយ"។ លោកបាន បន្ថែមទៀតថា លោកបានទទួលផែនទី១ស៊េរី ដើម្បីបញ្ជូនទៅឱ្យរដ្ឋមន្ត្រីក្រសួងការបរទេស សៀម។ លោកបានបន្តរៀបរាប់អំពីបញ្ជីឈ្មោះផែនទីទាំង១១ផ្ទាំង ដែលមួយផ្ទាំងមាន ៥០ច្បាប់ រួមទាំងផែនទីតំបន់ភ្នំដងរែកផង។ នៅចុងបញ្ចប់ លោកបាននិយាយថាគាត់ រក្សាទុកផែនទីនីមួយៗចំនួន២ច្បាប់ ហើយមួយច្បាប់ទៀតផ្ញើទៅស្ថានបេសកកម្មការទូត នីមួយៗ នៅទីក្រុងឡុង ប៊ែកឡាំង ប្រទេសរុស្ស៊ី និងសហរដ្ឋអាមេរិក។

មានការជំទាស់ក្នុងនាមប្រទេសថៃថា ការបញ្ជូនផែនទីដោយអាជ្ញាធរបារាំងនេះ បើនិយាយឱ្យចំទៅគឺធ្វើដោយភាគីតែម្ខាងទេ ហើយថាប្រទេសថៃមិនត្រូវបានស្នើសុំឬបាន បញ្ជាក់ថាខ្លួនបានទទួលផែនទីនេះជាផ្លូវការឡើយ។ តាមពិតទៅ ដូចដែលគេនឹងឃើញ ជាបន្តបន្ទាប់ទៀត ការទទួលស្គាល់ដែលត្រូវធ្វើឡើងតាមរបៀបមួយយ៉ាងច្បាស់លាស់ គឺតាមរយៈឥរិយាបថរបស់ថៃ។ ប៉ុន្តែ បើទុកជាមិនដូចនេះក៏ដោយ ក៏ច្បាស់ណាស់ថា មានកាលៈទេសៈជាច្រើនសម្រាប់ឱ្យអាជ្ញាធរសៀមមានប្រតិកម្មក្នុងរយៈពេលសមរម្យ ប្រសិនបើខ្លួនមានបំណងមិនយល់ព្រមនឹងផែនទីនេះ ឬមានបញ្ហាធ្ងន់ធ្ងរណាមួយត្រូវលើក ឡើងទាក់ទងនឹងផែនទីនេះ។ អាជ្ញាធរសៀមមិនបានបញ្ចេញប្រតិកម្មបែបនេះទេ ទាំងនៅ ពេលនោះឬអស់ជាច្រើនឆ្នាំបន្ទាប់មក ដូច្នេះហើយត្រូវចាត់ទុកថាបានសុខចិត្តទទួលយក។

ចំពោះផែនទីឧបសម្ព័ន្ធ១ វាមិនគ្រាន់តែជាកាលៈទេសៈនៃការបញ្ជូនផែនទីនេះ និងផែនទីដទៃទៀតនោះទេ ដែលបង្កឱ្យមានប្រតិកម្មពីភាគីសៀម ប្រសិនបើប្រតិកម្មនេះ

មានមែននោះ។ ប៉ុន្តែ ក៏មានការចង្អុលបង្ហាញផងដែរ នៅលើផ្ទៃនៃសន្លឹកផែនទីដែលតម្រូវឱ្យមានប្រតិកម្ម ប្រសិនបើអាជ្ញាធរសៀមមានហេតុផលជំទាស់ថាផែនទីនោះ មិនតំណាងឱ្យលទ្ធផលនៃការងារកំណត់ព្រំដែនទេ។ ដូចដែលបានពិពណ៌នារួចមកហើយ ផែនទីនេះ រួមជាមួយផែនទីដទៃទៀត ត្រូវបានប្រគល់ទៅឱ្យសមាជិកសៀមនៃគណៈកម្មការចម្រុះ។ សមាជិកទាំងនេះចាំបាច់ត្រូវតែដឹង (និងតាមរយៈពួកគេនោះ រដ្ឋាភិបាលសៀមត្រូវតែបានដឹង) ថាផែនទីនេះមិនអាចតំណាងឱ្យអ្វីៗដែលត្រូវបានអនុម័តជាផ្លូវការដោយគណៈកម្មការចម្រុះទេ ហើយដោយហេតុនេះពួកគេមិនអាចត្រូវបានច្រឡំដោយសារចំណងជើងផែនទីដែលមានឈ្មោះថា "ដងរែក-គណៈកម្មការកំណត់ព្រំដែនរវាងឥណ្ឌូចិន និងសៀម" ហើយមិនអាចនាំទៅដល់ការសន្មតថា វាជាការអះអាងនូវសមិទ្ធផលរបស់គណៈកម្មការចម្រុះនោះទេ។ ម៉្យាងទៀត ប្រសិនបើសមាជិកនៃគណៈកម្មការសៀមសន្មតផ្សេងពីនេះ ទោះបីមិនបានបញ្ជាក់ក្នុងកំណត់ហេតុក៏ដោយ ក៏ការណ៍នេះអាចកើតមានពីព្រោះថា តាមការពិតគណៈកម្មការចម្រុះបានធ្វើសេចក្ដីសម្រេចដែលជាមូលដ្ឋានសម្រាប់យកមកធ្វើផែនទី ហើយដោយសារការសម្រេចនេះ សមាជិកគណៈកម្មការសៀមពិតជាបានដឹងរួចទៅហើយ។

សមាជិកគណៈកម្មការសៀម ត្រូវតែបានឃើញផងដែរនូវកំណត់សម្គាល់ដែលមាននៅជ្រុងខាងលើប៉ែកខាងឆ្វេងនៃសន្លឹកផែនទីដែលបង្ហាញថា ការងារនៅលើដីជាក់ស្ដែងត្រូវបានប្រតិបត្តិដោយអនុសេនីយ៍ឯក Kerler និង អ៊ុំ ។ ដោយសារតែអ្នកទាំងនោះបានមានវត្តមាននៅក្នុងអង្គប្រជុំរបស់គណៈកម្មការ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩០៦ ដូច្នេះ ពួកគេត្រូវតែបានដឹងថា នៅពេលនោះអនុសេនីយ៍ឯក អ៊ុំ បានទទួលបញ្ជាឱ្យទៅធ្វើការវាស់វែងនៅប៉ែកខាងកើតនៃជួរភ្នំដងរែក ដែលគ្របដណ្ដប់ទាំងព្រះវិហារផងដែរ ហើយក៏ដឹងដែរថា គាត់ត្រូវចាកចេញនៅថ្ងៃបន្ទាប់ដើម្បីអនុវត្តការងារនេះ។ អ្នកទាំងនោះមិនបាននិយាយអ្វីទាំងអស់ ទាំងនៅពេលនោះនិងក្រោយៗមកទៀតដើម្បីស្នើសុំថា ផែនទីនេះមិនមែនជាលទ្ធផលនៃការងារកំណត់ព្រំដែនទេឬផែនទីនេះមានភាពមិនត្រឹមត្រូវក៏ទេដែរ។

ការណ៍ដែលអាជ្ញាធរសៀមតាមរយៈឥរិយាបថរបស់ខ្លួនបានបញ្ជាក់ថាបានទទួលផែនទីទាំងនោះនិងទទួលស្គាល់នូវលក្ខណៈនៃផែនទីទាំងនោះ និងអ្វីដែលផែនទីទាំងនោះតំណាងឱ្យ គឺត្រូវបានបង្ហាញតាមរយៈសកម្មភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រះអង្គម្ចាស់ដាម រ៉ុង ក្នុងការថ្លែងអំណរគុណចំពោះឯកអគ្គរដ្ឋទូតបារាំងនៅទីក្រុងបាងកក ចំពោះផែនទីទាំងនេះ និងស្នើសុំឱ្យលោកឯកអគ្គរដ្ឋទូតផ្តល់១៥ច្បាប់ទៀតនៃផែនទីនីមួយៗ ដើម្បីបញ្ជូនទៅឱ្យអភិបាលខេត្តរបស់សៀមជាច្រើនទៀតផង។

ភស្តុតាងបន្ថែមទៀត ត្រូវបានយកចេញពីការពិភាក្សាគ្នារបស់គណៈកម្មការប្រតិចារឹក (Commission of Transcription) ជាបន្តបន្ទាប់ ដែលបានជួបប្រជុំគ្នានៅទីក្រុងបាងកក នៅខែមីនា ឆ្នាំ១៩០៩ និងប៉ុន្មានខែក្រោយមកទៀត។ នេះគឺជាគណៈកម្មការចម្រុះបារាំង-សៀមមួយ ដែលត្រូវបានបង្កើតឡើងដោយភាគីទាំងពីរដែលមានគោលបំណងចាប់ផ្តើមការងារភូមិសាស្ត្ររបស់សៀមជាផ្លូវការ តាមរយៈការបញ្ចូលគ្នានូវរាល់ការងារទាំងអស់របស់គណៈកម្មការចម្រុះទាំងពីរ ឆ្នាំ១៩០៤និង១៩០៧។ គោលបំណងសំខាន់គឺត្រូវបំប្លែងផែនទីដែលមានស្រាប់ឱ្យទៅជាទម្រង់សៀវភៅផែនទីស្រួលមើលនិងធ្វើឱ្យពាក្យពេចន៍បារាំង-សៀម ដែលប្រើប្រាស់ក្នុងផែនទីនោះសមមូលត្រឹមត្រូវនៅក្នុងភាសាដទៃទៀត។ នៅក្នុងពេលបំពេញការងាររបស់គណៈកម្មការនេះ មិនមានការស្នើសុំណាមួយត្រូវបានធ្វើឡើងថា ផែនទីឧបសម្ព័ន្ធ១ឬខ្សែបន្ទាត់នេះមិនអាចទទួលយកបាននោះទេ។

មានការទាមទារក្នុងនាមថៃថា ផែនទីដែលទទួលបានពីក្រុងប៉ារីសនោះ បានឃើញដោយមន្ត្រីតូចតាចដែលមិនមានជំនាញខាងផែនទីតែប៉ុណ្ណោះ និងមិនបានដឹងអ្វីទាំងអស់អំពីប្រាសាទព្រះវិហារ។ តាមពិត នៅក្នុងរយៈពេលនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ មានការលើកឡើងថា គ្មាននរណាម្នាក់នៅប្រទេសសៀមនៅពេលនោះបានដឹងអំពីប្រាសាទព្រះវិហារឬខ្វល់ខ្វាយអំពីប្រាសាទនេះទេ។

តុលាការមិនអាចទទួលយកនូវការជំទាស់នេះទេ ទាំងអង្គហេតុ ទាំងអង្គច្បាប់។ ប្រសិនបើអាជ្ញាធរសៀមពិតជាបានបង្ហាញផែនទីទាំងនេះដល់តែមន្ត្រីតូចតាច នោះអាជ្ញាធរសៀមពិតជាបានធ្វើសកម្មភាពយ៉ាងប្រថុយប្រថាននេះដោយខ្លួនឯង ហើយតាមរយៈអង្គហេតុនេះ ការទាមទាររបស់ថៃមិនអាចទទួលបាននូវការគាំទ្រលើឆាកអន្តរជាតិឡើយ។

ប៉ុន្តែ ដូចដែលបានលើកឡើងខាងលើ ប្រវត្តិនៃរឿងរ៉ាវនេះបង្ហាញច្បាស់ថាផែនទីនេះត្រូវបានឃើញដោយបុគ្គលជាច្រើនដូចជា ព្រះអង្គម្ចាស់ ដេ វ៉ាវង្សសេ ជារដ្ឋមន្ត្រីការបរទេស ព្រះអង្គម្ចាស់ ដាម រ៉ុង ជារដ្ឋមន្ត្រីមហាផ្ទៃ សមាជិកសៀមរបស់គណៈកម្មការចម្រុះទី១ សមាជិកសៀមរបស់គណៈកម្មការប្រតិចារឹក និងត្រូវបានសន្និដ្ឋានផងដែរថា ផែនទីឧបសម្ព័ន្ធ១នេះ ត្រូវបានឃើញដោយអភិបាលខេត្តខូកខាន់ (Khukhan) ជាខេត្តរបស់សៀម នៅជាប់នឹងតំបន់ព្រះវិហារភាគខាងជើង ដែលគាត់ជាអភិបាលខេត្តម្នាក់ក្នុងចំណោមអភិបាលខេត្តមួយចំនួនដែលត្រូវទទួលបានផែនទីថតចម្លងបន្ថែម ដែលត្រូវបានស្នើសុំបន្ថែមដោយព្រះអង្គម្ចាស់ ដាម រ៉ុង។ មិនមានបុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលទាំងនេះជាមន្ត្រីតូចតាចនោះទេ។ មន្ត្រីទាំងអស់ឬស្ទើរតែទាំងអស់ស្គាល់ភូមិសាស្ត្រនៅតំបន់នោះ។ មន្ត្រីខ្លះទៀតប្រាកដជាស្គាល់តំបន់ដងរែក។ តាមរយៈឯកសារនៅក្នុងសំណុំរឿងបង្ហាញច្បាស់ថា ព្រះអង្គម្ចាស់ ដាម រ៉ុង មានចំណាប់អារម្មណ៍ផ្ទាល់ខ្លួនយ៉ាងខ្លាំងលើការងារកំណត់ព្រំដែននេះនិងមានចំណេះដឹងជ្រាលជ្រៅអំពីប្រាសាទបុរាណ។ វាមិនអាចជឿបានទាល់តែសោះដែលថា អភិបាលខេត្តខូកខាន់ (Khukhan) ដែលជាខេត្តបង្កើតឡើងជាប់ជាមួយព្រះវិហារ រហូតដល់មានដំណោះស្រាយនៅឆ្នាំ១៩០៤ មិនដឹងអំពីអត្ថិភាពរបស់ប្រាសាទព្រះវិហារនោះទេ។

ទោះជាករណីណាក៏ដោយ ការជំទាស់ជាលក្ខណៈពិសេសរបស់ថៃនេះ ត្រូវបានបដិសេធយ៉ាងច្បាស់ក្រឡែត តាមរយៈឯកសារមួយដែលថៃខ្លួនឯងបានតម្កល់ ហើយតាមឯកសារនោះ ប្រាសាទនេះត្រូវបានរកឃើញជាថ្មីនៅឆ្នាំ១៨៩៩ ដោយព្រះអង្គម្ចាស់សៀមឈ្មោះ សានផាស៊ីត អមដំណើរដោយមន្ត្រី និងអ្នកមុខអ្នកការមូលដ្ឋានប្រហែល១៥ទៅ២០នាក់ ដែលក្នុងនោះទំនងជាមានអភិបាល និងអភិបាលរងខេត្តខូកខាន់ (Khukhan) ផងដែរ។ ដូចនេះវាបង្ហាញឱ្យឃើញថា គ្រាន់តែក្នុងរយៈពេល៩ឆ្នាំប៉ុណ្ណោះ មុនពេលអាជ្ញាធរសៀមទទួលបានផែនទីឧបសម្ព័ន្ធ១នេះ មានមន្ត្រីជាន់ខ្ពស់ជាច្រើននៅប្រទេសសៀមបានដឹងអំពីព្រះវិហារ។

លើសពីនេះទៀត តុលាការយល់ឃើញថាមិនមានមូលដ្ឋានច្បាប់ចំពោះបច្ច័យដែលខ្លួនព្យាយាមទាញយកសេចក្តីស្នើសុំចេញពីអង្គហេតុថា នៅពេលនោះមិនមាននរណា

ម្នាក់នៅប្រទេសថៃ បានដឹងអំពីសារៈសំខាន់នៃប្រាសាទឬខ្វល់ខ្វាយអំពីប្រាសាទព្រះវិហារ។ តាមផ្លូវច្បាប់ ការកែតម្រូវព្រំដែនមិនអាចទាមទារដោយឈរលើមូលដ្ឋានថា តំបន់ព្រំដែនមួយប្រែជាមានសារៈសំខាន់ ដោយមិនបានដឹងឬមិនសង្ស័យនៅពេលបង្កើតព្រំដែននោះទេ។

*

* *

តាមការរកឃើញជាហូរហែបានឱ្យដឹងថា អាជ្ញាធរសៀមពិតជាបានទទួលដោយត្រឹមត្រូវនូវផែនទីឧបសម្ព័ន្ធ១នេះ ហើយថាអាជ្ញាធរសៀមបានព្រមទទួលយកផែនទីនេះ។ ប៉ុន្តែនៅពេលនេះ ពាក់ព័ន្ធទៅនឹងតំបន់នៃព្រះវិហារដែលសព្វថ្ងៃមានការជំទាស់ក្នុងនាមប្រទេសថៃ ថាមានកំហុសដែលត្រូវបានប្រព្រឹត្តជាកំហុសដែលអាជ្ញាធរសៀមមិនបានដឹងនៅពេលដែលខ្លួនព្រមទទួលយកផែនទីនាពេលនោះ។

តាមវិធាននៃច្បាប់គឺថា ភាគីមួយមិនត្រូវបានអនុញ្ញាតឱ្យលើកឡើងអំពីកំហុសថា ជាធាតុផ្សំដើម្បីធ្វើឱ្យទៅជាមោឃៈនូវការយល់ព្រមបានទេ ប្រសិនបើភាគីដែលលើកឡើងនោះបានរួមចំណែកប្រព្រឹត្តកំហុស ដោយឥរិយាបថខ្លួនឯងឬអាចបញ្ចៀសកំហុសបាន ឬប្រសិនបើក្នុងស្ថានភាពដែលភាគីនោះមានលទ្ធភាពដឹងអំពីកំហុសដែលអាចកើតមាន។ តុលាការយល់ឃើញថាគ្រាន់តែគុណសម្បត្តិនិងសមត្ថភាពរបស់បុគ្គលនៃភាគីថៃដែលបានឃើញផែនទីឧបសម្ព័ន្ធ១តែប៉ុណ្ណោះ ក៏នឹងធ្វើឱ្យមានការលំបាកចំពោះប្រទេសថៃ ក្នុងការអះអាងអំពីកំហុសនេះណាស់តាមផ្លូវច្បាប់។ អ្នកទាំងនេះរាប់បញ្ចូលទាំងសមាជិកនៃគណៈកម្មការព្រំដែននេះតែម្តង ដែលខ្លួនមានសមត្ថកិច្ចលើផ្នែកនេះនៃព្រំដែន។ ប៉ុន្តែក្រៅពីនេះតុលាការយល់ឃើញថា មានកាលៈទេសៈផ្សេងទៀតជាច្រើនពាក់ព័ន្ធនឹងផែនទីឧបសម្ព័ន្ធ១នេះ ដែលធ្វើឱ្យការអះអាងអំពីកំហុសនេះលំបាកនឹងទទួលយក។

ការពិនិត្យពិច័យមួយបង្ហាញថា ផែនទីនេះបានទាញការចាប់អារម្មណ៍យ៉ាងស្រួចស្រាល់ចំពោះតំបន់ព្រះវិហារ ដែលគ្មានបុគ្គលពាក់ព័ន្ធឬគ្មានបុគ្គលណាម្នាក់មានភារកិច្ចពិនិត្យពិច័យផែនទី អាចខកខានមិនបានឃើញអ្វីដែលបានបង្ហាញនៅក្នុងផែនទី

ពាក់ព័ន្ធនឹងតំបន់នោះទេ។ ដូចដែលប្រទេសថៃបានលើកឡើង ប្រសិនបើរូបសណ្ឋានភូមិសាស្ត្រនៃទីកន្លែងនោះ ផ្តល់លក្ខណៈច្បាស់លាស់ចំពោះនរណាក៏ដោយដែលធ្លាប់ទៅដល់ទីនោះ ពិតជាឃើញថាខ្សែបែងចែកទឹកត្រូវដើរតាមបណ្តោយខ្សែចំណោតថ្ម (ប្រសិនបើការណ៍នេះពិតមែននោះ អង្គហេតុនេះពិតជាមានយ៉ាងច្បាស់ណាស់នៅឆ្នាំ១៩០៨) ដូច្នេះ ផែនទីនេះបានបង្ហាញឱ្យឃើញច្បាស់ថា ខ្សែបន្ទាត់របស់ផែនទីឧបសម្ព័ន្ធ១មិនបានដើរទៅតាមខ្សែចំណោតថ្មទេនៅក្នុងតំបន់នោះ ដោយហេតុថាខ្សែបន្ទាត់នេះត្រូវបានគូសឱ្យនៅឆ្ងាយទៅខាងជើងពយនៃភ្នំព្រះវិហារទាំងមូល។ គ្មាននរណាម្នាក់ដែលមើលផែនទីនេះ ហើយយល់ច្រឡំអំពីផែនទីនេះនោះទេ។

លើសពីនេះទៅទៀត ផែនទីនេះបានកំណត់យ៉ាងច្បាស់នូវទីតាំងប្រាសាទព្រះវិហារស្ថិតក្នុងទឹកដីកម្ពុជា ដោយប្រើរូបសញ្ញាដែលហាក់ដូចជាការបង្ហាញនូវប្លង់គ្រួសៗនៃទីតាំងប្រាសាទនិងកាំជណ្តើរដែលតំណាងឱ្យប្រាសាទនេះ។

ដូច្នេះ វាហាក់ដូចជាមានព័ត៌មានគ្រប់គ្រាន់ហើយ នៅក្នុងផែនទីឧបសម្ព័ន្ធ១ដើម្បីកាត់មន្ទិលសង្ស័យ ចំពោះអ្នកដែលមានភារកិច្ចត្រូវពិនិត្យពិច័យផែនទីនេះឬចំពោះនរណាក៏ដោយដែលបានគិតថា ខ្សែបែងចែកទឹកនៅតំបន់ព្រះវិហារគួរតែដើរតាមខ្សែចំណោតថ្ម។ ហួសពីនេះទៅទៀត ដូចដែលបានចង្អុលបង្ហាញរួចមកហើយ រដ្ឋាភិបាលសៀមបានដឹងឬត្រូវបានសន្មតថាបានដឹងតាមរយៈសមាជិកសៀមនៃគណៈកម្មការចម្រុះ ថាផែនទីឧបសម្ព័ន្ធ១មិនដែលត្រូវបានអនុម័តជាផ្លូវការដោយគណៈកម្មការនេះទេ។ អាជ្ញាធរសៀមបានដឹងរួចហើយថា ផែនទីនេះគឺជាលទ្ធផលការងាររបស់មន្ត្រីឋានលេខាសាស្ត្របារាំងដែលអាជ្ញាធរសៀមខ្លួនឯងបានផ្តល់ជំនឿទុកចិត្តឱ្យធ្វើការងារផលិតផែនទីទាំងនេះ។ អាជ្ញាធរសៀមបានព្រមទទួលយកផែនទីនេះដោយមិនបានធ្វើការស្រាវជ្រាវឯករាជ្យណាមួយ ដូចនេះហើយឥឡូវនេះ អាជ្ញាធរសៀមមិនអាចអះអាងអំពីកំហុសដើម្បីលុបចោលនូវការយល់ព្រមពិតប្រាកដរបស់ពួកគេនោះបានទេ។ ហេតុដូច្នេះហើយ តុលាការសន្និដ្ឋានថា ការលើកឡើងអំពីកំហុសមិនអាចយកជាការបានទេ។

ឥឡូវតុលាការនឹងពិចារណាលើព្រឹត្តិការណ៍នានាក្រោយដំណាក់កាលឆ្នាំ១៩០៤-១៩០៩។

ពីមុនមក អាជ្ញាធរសៀមមិនបានលើកសំណួរណាមួយអំពីផែនទីឧបសម្ព័ន្ធ១ រវាងខ្លួនឯងនិងបារាំងឬកម្ពុជា ឬបដិសេធផែនទីនេះជាចំហនោះទេ រហូតដល់ការចរចាឆ្នាំ ១៩៥៨ នៅទីក្រុងបាងកក ទើបអាជ្ញាធរសៀមលើកយកបញ្ហាផែនទីឧបសម្ព័ន្ធ១មកនិយាយ និងបដិសេធផែនទីនេះជាចំហនៅក្នុងការពិភាក្សារវាងថៃនិងកម្ពុជា អំពីបញ្ហាប្រាសាទព្រះវិហារក្នុងចំណោមបញ្ហាផ្សេងទៀត។ ពុំមានបញ្ហាណាមួយត្រូវបានលើកឡើង សូម្បីតែក្រោយឆ្នាំ១៩៣៤-១៩៣៥ នៅពេលដែលថៃធ្វើការវាស់វែងដោយខ្លួនឯងនៅក្នុងតំបន់នេះ ហើយតាមទស្សនៈរបស់ថៃ ការវាស់វែងនេះបង្ហាញថាមានភាពខុសគ្នារវាងខ្សែបន្ទាត់នៅលើផែនទីនិងខ្សែបែងចែកទឹកពិតប្រាកដ ដែលភាពខុសគ្នាមួយនាំទៅដល់ការដាក់ប្រាសាទព្រះវិហារក្នុងទឹកដីកម្ពុជា។ ក្រោយកាលបរិច្ឆេទនេះមក ទោះបីថៃពេលខ្លះបានផលិតផែនទីមួយចំនួនដោយខ្លួនឯងដែលបង្ហាញថា ប្រាសាទព្រះវិហារស្ថិតក្នុងទឹកដីថៃក៏ដោយ ក៏ថៃនៅតែបន្តប្រើប្រាស់ទាំងសម្រាប់គោលបំណងផ្លូវការនិងសាធារណៈនូវផែនទីឧបសម្ព័ន្ធ១ឬផែនទីដទៃទៀតដែលបានបង្ហាញថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីកម្ពុជាដោយមិនបានលើកឡើងនូវសំណួរណាមួយអំពីបញ្ហានេះទេ (ការពន្យល់របស់ថៃ អំពីបញ្ហានេះនឹងត្រូវយកមកពិចារណានាពេលក្រោយ)។ លើសពីនេះទៀត តុលាការមានការលំបាកនឹងមើលរំលងនូវហេតុការណ៍ដែលថា ជាឧទាហរណ៍ នៅឆ្នាំ១៩៣៧ ក្រោយពីការវាស់វែងដោយថៃខ្លួនឯងនៅឆ្នាំ១៩៣៤-១៩៣៥ ហើយដែលនៅឆ្នាំដដែលនោះមានការចុះសន្ធិសញ្ញាជាមួយបារាំង ដែលក្នុងនោះមានការអះអាងឡើងវិញនូវព្រំដែនរួមដែលបានកំណត់រួចហើយ អគ្គនាយកដ្ឋានភូមិសាស្ត្រភូមិន្ទសៀមបានផលិតផែនទីមួយបង្ហាញថាព្រះវិហារស្ថិតនៅក្នុងទឹកដីកម្ពុជា។

ថៃមានឱកាសជាច្រើនដង ដើម្បីលើកឡើងអំពីបញ្ហាផែនទីឧបសម្ព័ន្ធ១ជាមួយអាជ្ញាធរបារាំង។ ជាបឋម មានការចរចាលើសន្ធិសញ្ញាឆ្នាំ១៩២៥និង១៩៣៧ ស្តីពីមិត្តភាពពាណិជ្ជកម្មនិងនាវាចរណ៍រវាងបារាំងក្នុងនាមឥណ្ឌូចិននិងសៀម។ បើទុកជាសន្ធិសញ្ញាទាំងនេះបានចែងអំពីនីតិវិធីទូទៅសម្រាប់សើរើឡើងវិញឬជំនួសកិច្ចព្រមព្រៀងមុនៗ ក៏សន្ធិសញ្ញាទាំងនេះមិនរាប់បញ្ចូលព្រំដែន ដែលមានស្រាប់ក្នុងនីតិវិធីដែរ ដោយហេតុថាព្រំដែននេះត្រូវបានកំណត់តាមដំណោះស្រាយព្រំដែននៅឆ្នាំ១៨៩៣ ១៩០៤ និង១៩០៧ រួចហើយ។ ហេតុដូច្នេះហើយ និងតាមបទប្បញ្ញត្តិជាក់ស្តែងមួយចំនួនទៀត ភាគីទាំងពីរ

បានតម្កល់ទុកជាបានការចំពោះព្រំដែនដែលមានស្រាប់ ទោះបីព្រំដែននោះយ៉ាងណាក៏ដោយ។ ទាំងនេះគឺជាឱកាសដែលតាមធម្មតាថៃគួរតែបានលើកបញ្ហានេះ ប្រសិនបើខ្លួនយល់ឃើញថាផែនទីនេះចង្អុលបង្ហាញព្រំដែននៅត្រង់ព្រះវិហារមិនត្រឹមត្រូវ (ជាពិសេសទាក់ទងនឹងការចរចាសន្ធិសញ្ញាឆ្នាំ១៩៣៧ ដែលធ្វើឡើងតែ២ឆ្នាំប៉ុណ្ណោះបន្ទាប់ពីការវាស់វែងដោយថៃខ្លួនឯងលើតំបន់ព្រំដែននេះ ដែលបានបង្ហាញឱ្យឃើញតាមការយល់ឃើញរបស់ថៃថា មានភាពខុសគ្នាយ៉ាងខ្លាំងរវាងខ្សែបន្ទាត់លើផែនទីនិងខ្សែបែងចែកទឹកនៅត្រង់ព្រះវិហារ) ដែលក្នុងឱកាសទាំងនោះថៃគួរតែបាន និងត្រូវតែលើកបញ្ហានេះឡើងប្រសិនបើថៃជឿជាក់ថាដូច្នោះមែន។ ជាក់ស្តែង ថៃមិនត្រឹមតែមិនបានលើកឡើងប៉ុណ្ណោះទេ ប៉ុន្តែថៃមទាំងផលិតផែនទីមួយដោយខ្លួនឯងនៅឆ្នាំ១៩៣៧ ដែលបង្ហាញថា ព្រះវិហារស្ថិតនៅក្នុងទឹកដីកម្ពុជាទៀតផង។ ទោះជាផែនទីនេះ ធ្វើឡើងក្នុងបំណងយកមកប្រើប្រាស់សម្រាប់គោលដៅផ្ទៃក្នុងយោធាក៏ដោយ ប៉ុន្តែវាមិនបានធ្វើឱ្យតុលាការយល់ឃើញថា វាមិនមានតម្លៃជាភស្តុតាងទេក្នុងទស្សនៈរបស់ប្រទេសថៃនោះ។ គេអាចធ្វើការសន្និដ្ឋានថាជាពិសេសនៅក្នុងកាលៈទេសៈឆ្នាំ១៩៣៧ ថៃបានឬនៅតែបានព្រមទទួលយកផែនទីនៃឧបសម្ព័ន្ធ១ និងខ្សែបន្ទាត់ដែលផែនទីនេះបានចង្អុលបង្ហាញ ទោះបីថៃយល់ថា វាមិនត្រឹមត្រូវ និងទោះបីក្រោយពេលខ្លួនបានធ្វើការវាស់វែងដោយខ្លួនឯងនៅឆ្នាំ១៩៣៤-១៩៣៥ក៏ដោយ ថៃបានគិតថាខ្លួនបានដឹងថា ផែនទីនេះមិនត្រឹមត្រូវ។

នៅពេលដែលថៃបានចូលកាន់កាប់ជាបណ្តោះអាសន្នផ្ទៃកមួយចំនួននៃប្រទេសកម្ពុជា រួមទាំងព្រះវិហារនៅឆ្នាំ១៩៤១ ក្រសួងព័ត៌មានថៃបានបោះពុម្ពផ្សាយស្នាដៃមួយមានចំណងជើងថា "ថៃក្នុងពេលស្តារប្រទេសជាតិឡើងវិញ" ដែលក្នុងនោះបាននិយាយពាក់ព័ន្ធដល់ព្រះវិហារថា ឥឡូវប្រាសាទព្រះវិហារត្រូវបានប្រទេសថៃយកមកវិញហើយ។ ចំណុចខាងលើនេះ ត្រូវបានថៃបកស្រាយថាជាកំហុសរបស់មន្ត្រីតូចតាចម្នាក់។ ម៉្យាងទៀតភាសាស្រដៀងគ្នានេះ ដែលត្រូវបានប្រើប្រាស់ដោយតំណាងរបស់ថៃនៅក្នុងការចរចាទឹកដីរវាងកម្ពុជានិងថៃ នៅទីក្រុងបាងកក នៅឆ្នាំ១៩៥៨ បង្ហាញថាថៃទើបតែបានចូលកាន់កាប់ព្រះវិហារក្នុងប្រហែលឆ្នាំ១៩៤០ប៉ុណ្ណោះ។

បន្ទាប់ពីសង្គ្រាមរួច តាមរយៈកិច្ចព្រមព្រៀងដំណោះស្រាយខែវិច្ឆិកា ឆ្នាំ១៩៤៦ ជាមួយបារាំង ថៃបានទទួលយកនូវការត្រឡប់ទៅរកស្ថានភាពដើម (status quo ante) ដូចមុនឆ្នាំ១៩៤១វិញ។ ថៃអះអាងថាការវិលត្រឡប់ទៅរកស្ថានភាពដើមនេះ (status quo) មិនប៉ះពាល់ដល់តំបន់ព្រះវិហារទេ ដោយសារថៃបានមានអធិបតេយ្យលើតំបន់នេះតាំងពីមុនសង្គ្រាមម្ល៉េះ។ តុលាការមិនចាំបាច់ពិភាក្សាលើការអះអាងនេះទេ ពីព្រោះបញ្ហាដែលថាតើថៃមានឬពុំមានអធិបតេយ្យនោះ គឺជាបញ្ហាច្បាស់លាស់នៅក្នុងនីតិវិធីនេះហើយ។ បន្ទាប់ពីព្រឹត្តិការណ៍សង្គ្រាមរួចមក ចំណុចសំខាន់នោះគឺថា បារាំងព្រមព្រៀងបង្កើតគណៈកម្មការសម្រុះសម្រួលបារាំង-សៀម ដែលរួមមានតំណាងពីររូបមកពីភាគីនីមួយៗនិងសមាជិកអព្យាក្រឹតបីរូប ដែលមានភារកិច្ចជាពិសេសពិនិត្យនិងផ្តល់អនុសាសន៍ដោយឈរលើមូលដ្ឋានសមធម៌ចំពោះរាល់បណ្តឹងឬសំណើសុំសើរើឡើងវិញ ដែលថៃអាចមានបំណងនឹងស្នើឡើងអំពីការដោះស្រាយព្រំដែនឆ្នាំ១៩០៤និង១៩០៧ ក្នុងចំណោមបញ្ហាដទៃទៀត។ គណៈកម្មការនេះបានជួបប្រជុំគ្នានៅឆ្នាំ១៩៤៧ នៅទីក្រុងវ៉ាស៊ីនតោន ហើយនៅទីនោះហើយ ដែលជាឱកាសដ៏ប្រសើរសម្រាប់ថៃទាមទារឱ្យធ្វើការកែតម្រូវព្រំដែននៅតំបន់ព្រះវិហារដោយឈរលើមូលដ្ឋានថា ការកំណត់ព្រំដែននេះមានកំហុសធ្ងន់ធ្ងរដែលអាចនាំឱ្យថៃបដិសេធការកំណត់ព្រំដែននេះ ប្រសិនបើខ្លួនបានដឹងអំពីកំហុសនេះនៅឆ្នាំ១៩០៨-១៩០៩ មែននោះ។ តាមពិត បើទុកជាថៃបានប្តឹងជាច្រើនដងអំពីខ្សែព្រំដែននៅក្នុងតំបន់ជាច្រើនក៏ដោយ ក៏ថៃមិនបានប្តឹងទាល់តែសោះអំពីតំបន់ព្រះវិហារ។ មិនត្រឹមតែប៉ុណ្ណោះ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៤៧ ថៃថែមទាំងបានដាក់ជូនទៅគណៈកម្មការនូវផែនទីមួយដែលបង្ហាញថាព្រះវិហារស្ថិតនៅក្នុងប្រទេសកម្ពុជាទៀតផង។ ថៃអះអាងថា ការណ៍នេះមិនមានផលប៉ះពាល់ជាអវិជ្ជមានចំពោះការទាមទារសិទ្ធិលើប្រាសាទទេ ពីព្រោះតំបន់ប្រាសាទមិនមែនជាកម្មវត្ថុនៃការពិភាក្សារបស់គណៈកម្មការនេះទេ គឺតំបន់ផ្សេងទៀតដែលជាកម្មវត្ថុនៃការពិភាក្សានេះ ហើយគឺផែនទីដែលទាក់ទងនឹងតំបន់ទាំងនោះទេដែលត្រូវបានយកមកប្រើប្រាស់។ ប៉ុន្តែអង្គហេតុបង្ហាញច្បាស់លាស់ថា ថៃបានលើកបញ្ហាដទៃទៀតជាច្រើន ប៉ុន្តែមិនបានលើកអំពីបញ្ហាព្រះវិហារដែលតម្រូវឱ្យមានការពន្យល់ទេ។ ដោយមិនគិតអំពីបញ្ហាផ្សេងទៀត យោងតាមហេតុការណ៍ដែលកើតឡើងមួយចំនួននៅមូលដ្ឋានទាក់ទងនឹងប្រាសាទនេះ ថៃបានដឹងយ៉ាងច្បាស់នៅពេលនោះថា បារាំងបាន

ចាត់ទុកថា ព្រះវិហារស្ថិតនៅក្នុងទឹកដីកម្ពុជា ដូចដែលបានបង្ហាញក្នុងផែនទីគូសដោយអាជ្ញាធរបារាំង និងបានបញ្ជូនឱ្យរដ្ឋាភិបាលសៀមនៅឆ្នាំ១៩០៨ បើទុកជាការណ៍នេះមិនបានបញ្ជាក់ច្បាស់ចេញពីខ្សែព្រំដែនក្តី។ ជាថ្មីម្តងទៀត ការសន្និដ្ឋានជាធម្មតាអំពីការខកខានរបស់ថៃក្នុងការលើកឡើងអំពីព្រះវិហារនៅក្នុងឱកាសនោះ គឺថាខ្លួនមិនបានត៉វាដូច្នោះ ពីព្រោះខ្លួនបានព្រមទទួលយកខ្សែព្រំដែនត្រង់ចំណុចនេះ ដូចដែលបានគូសនៅលើផែនទីដោយមិនគិតថាខ្សែព្រំដែននេះដើរឬមិនដើរតាមខ្សែបែងចែកទឹកទេ។

ចំពោះការប្រើប្រាស់ផែនទីដែលបង្ហាញថាព្រះវិហារស្ថិតក្នុងប្រទេសកម្ពុជា ថៃរក្សាជំហរថា នេះជាហេតុផលផ្នែកផែនទីសុទ្ធសាធ ហើយក៏គ្មានផែនទីដទៃទៀតទេ ឬក៏មិនមានផែនទីដែលងាយស្រួលប្រើ ឬមិនមានផែនទីណាដែលមានមាត្រដ្ឋានត្រឹមត្រូវក្នុងពេលនោះឡើយ។ តុលាការយល់ឃើញថាការពន្យល់នេះមិនអាចជឿបានទេ។ ជាមួយនឹងការបន្តប្រើប្រាស់ផែនទីនេះ ថៃគួរតែបានធ្វើការរក្សាសិទ្ធិបម្រុងជាមួយបារាំងចំពោះភាពត្រឹមត្រូវរបស់ផែនទីនេះ។ ប៉ុន្តែថៃមិនបានធ្វើដូច្នេះទេ។

ចំពោះការខកខានរបស់ថៃ សូម្បីតែលើកឡើងអំពីបញ្ហាផែនទីនេះរហូតដល់ឆ្នាំ១៩៥៨នោះ ថៃអះអាងថា ដោយសារខ្លួនបានកាន់កាប់ព្រះវិហារនៅគ្រប់សម័យកាលសំខាន់ៗទាំងអស់ ហេតុដូច្នេះហើយទើបថៃមិនចាំបាច់លើកបញ្ហានេះទេ។ ថៃបានការពារទង្វើរបស់ខ្លួនដោយផ្អែកលើសកម្មភាពជាក់ស្តែងនៅមូលដ្ឋានជាភស្តុតាង ថាខ្លួនមិនដែលព្រមទទួលយកខ្សែបន្ទាត់ឧបសម្ព័ន្ធ១នៅឯព្រះវិហារទាល់តែសោះ ហើយអះអាងថាបើខ្លួនមិនដែលបានព្រមទទួលយកខ្សែបន្ទាត់នោះផង ច្បាស់ណាស់ខ្លួនមិនចាំបាច់បដិសេធខ្សែបន្ទាត់នោះទេ ដូច្នេះហើយគេពុំអាចធ្វើសេចក្តីសន្និដ្ឋានជាអវិជ្ជមានណាមួយចេញពីការខកខានរបស់ខ្លួនក្នុងការធ្វើដូច្នោះទេ។ តម្លៃនៃការពន្យល់នេះ ត្រូវតែអាស្រ័យយ៉ាងពិតប្រាកដទៅលើចំណុចដែលត្រូវដឹងថា តើឥរិយាបថនៅលើដីជាក់ស្តែងរបស់ថៃ អាចផ្តល់ជាភស្តុតាងគ្រប់គ្រាន់ជាប្រតិសកម្ម *(ex post facto)* ដើម្បីបង្ហាញថា ខ្លួនមិនដែលព្រមទទួលយកខ្សែព្រំដែនរបស់ឧបសម្ពន្ធ័១ នៅឆ្នាំ១៩០៨ ទាក់ទងនឹងព្រះវិហារ និងចាត់ទុកខ្លួនឯងថាមានអធិបតេយ្យលើតំបន់ប្រាសាទនេះគ្រប់សម័យកាលសំខាន់ៗទាំងអស់បានដែរឬទេ។

*

*          *

តុលាការបានពិចារណាភស្តុតាងផ្តល់ដោយថៃ តាមរយៈសកម្មភាពរដ្ឋបាលរបស់មន្ត្រីខ្លួននៅតំបន់ព្រះវិហារឬពាក់ព័ន្ធនឹងព្រះវិហារ។ បារាំង ហើយក្រោយមកកម្ពុជាតាមឋានៈរបស់ខ្លួនដែលមានចែងនៅក្នុងអនុសញ្ញា១៩០៤ បានធ្វើតែសកម្មភាពរដ្ឋបាលតាមទម្លាប់បន្តិចបន្តួចតែប៉ុណ្ណោះនៅក្នុងតំបន់ដាច់ស្រយាលតូចមួយនេះ។ ថៃបានទទួលស្គាល់យ៉ាងច្បាស់លាស់នៅក្នុងពេលធ្វើសវនាការផ្ទាល់មាត់ថា បើកម្ពុជាទទួលបានអធិបតេយ្យលើតំបន់ប្រាសាទនេះតាមស្មារតីនៃដំណោះស្រាយព្រំដែនឆ្នាំ១៩០៤ ហើយក្រោយមកកម្ពុជាក៏មិនបានបោះបង់ចោលអធិបតេយ្យនេះទេ ចំណែកឯប្រទេសថៃមិនដែលបានទទួលអធិបតេយ្យនេះតាមរយៈអាជ្ញាយុកាលលទ្ធកម្មនេះទេ។ ដូច្នេះ សកម្មភាពជាក់ស្តែងរបស់ថៃត្រូវបានលើកឡើងជាភស្តុតាងនៃសកម្មភាព ជាអំណាចគ្រប់គ្រងដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបដិសេធចំពោះការលើកឡើងដែលថា តាមដំណោះស្រាយអនុសញ្ញាឆ្នាំ១៩០៤ ថៃបានព្រមទទួលយកការកំណត់ព្រំដែនដែលមានអានុភាពផ្តល់អធិបតេយ្យលើព្រះវិហារទៅឱ្យកម្ពុជា។ ដូច្នេះតាមទស្សនៈនេះ តុលាការត្រូវតែពិចារណានិងវាយតម្លៃលើសកម្មភាពទាំងនេះ។ បញ្ហាពិតប្រាកដគឺថា តើសកម្មភាពទាំងអស់នេះគ្រប់គ្រាន់ដើម្បីលុបចោលឬទុកជាមោឃៈដែរឬទេ នូវការបង្ហាញឆន្ទៈយ៉ាងច្បាស់អំពីការព្រមទទួលយកខ្សែព្រំដែននៅព្រះវិហារ ដែលជាលទ្ធផលនៃការពិចារណាដែលបានពិភាក្សាខាងលើរួចហើយនោះ។

សកម្មភាពដែលពាក់ព័ន្ធ គឺសុទ្ធតែជាសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាននិងថ្នាក់ខេត្តតែប៉ុណ្ណោះ លើកលែងតែករណីសំខាន់ៗមួយឬពីរដែលត្រូវលើកឡើងនាពេលនេះ។ នៅក្នុងកម្រិតដែលសកម្មភាពទាំងនេះបានកើតឡើង គេមិនច្បាស់ទេថាសកម្មភាពទាំងនេះ មានការពាក់ព័ន្ធនឹងកំពូលភ្នំព្រះវិហារនិងតំបន់ប្រាសាទផ្ទាល់ជាជាងពាក់ព័ន្ធនឹងកន្លែងក្បែរៗតំបន់នោះ។ ប៉ុន្តែទោះជាយ៉ាងក៏ដោយ តុលាការពិបាកនឹងចាត់ទុកថា សកម្មភាពថ្នាក់មូលដ្ឋានបែបនេះ ជាការធ្វើមោឃកម្មនិងជំទាស់នូវជំហរស៊ីចង្វាក់និងមិនប្រែប្រួលរបស់អាជ្ញាធរសៀមថ្នាក់កណ្តាលនេះ ទាក់ទងនឹងខ្សែព្រំដែនដូចមានគូសក្នុងផែនទី។

ទាក់ទងទៅនឹងរឿងនេះ ព្រឹត្តិការណ៍ដ៏សំខាន់បំផុតនោះគឺការធ្វើទស្សនកិច្ចទៅប្រាសាទព្រះវិហារក្នុងឆ្នាំ១៩៣០ ដោយព្រះអង្គម្ចាស់ ដាម រ៉ុង អតីតរដ្ឋមន្ត្រីមហាផ្ទៃ ហើយនៅពេលនោះជាប្រធានវិទ្យាស្ថានភូមិន្ទសៀមទទួលបន្ទុកការងារទាក់ទងនឹងបណ្ណាល័យជាតិនិងបូជនីយដ្ឋានបុរាណវត្ថុវិទ្យា។ ទស្សនកិច្ចនេះ គឺជាផ្នែកមួយនៃដំណើរទស្សនកិច្ចបុរាណវត្ថុវិទ្យារបស់ព្រះអង្គម្ចាស់ដោយមានការអនុញ្ញាតពីព្រះមហាក្សត្រសៀម និងដំណើរទស្សនកិច្ចនេះមានលក្ខណៈស្ទើរតែផ្លូវការយ៉ាងច្បាស់។ នៅពេលព្រះអង្គម្ចាស់ទៅដល់ព្រះវិហារ ព្រះអង្គម្ចាស់ត្រូវបានទទួលជាផ្លូវការដោយអ្នកតំណាងបារាំង ដែលប្រចាំនៅខេត្តរបស់កម្ពុជាក្នុងនាមអ្នកតំណាងជាន់ខ្ពស់បារាំងរបស់ខ្លួន ដោយមានបង្ហូតទង់ជាតិបារាំងទៀតផង។ ព្រះអង្គម្ចាស់ប្រហែលជាមិនទំនងជាមិនយល់នូវអត្ថន័យនៃការទទួលបែបនេះនោះទេ។ គេប្រហែលជានឹងពិបាករកអំណះអំណាងបញ្ជាក់ពីកម្មសិទ្ធិរបស់ភាគីឥណ្ឌូចិនបារាំងឱ្យច្បាស់ជាងនេះណាស់។ ការណ៍នេះ ទាមទារឱ្យមានប្រតិកម្ម តែថៃមិនមានប្រតិកម្មអ្វីសោះ។ លើសពីនេះទៀត នៅពេលព្រះអង្គម្ចាស់ ដាម រ៉ុង ត្រឡប់ទៅបាងកកវិញ បានផ្ញើរូបថតមួយចំនួននៃឱកាសនោះជូនអ្នកតំណាងបារាំងទៀតផង ព្រះអង្គបានប្រើភាសាដែលហាក់ដូចជាទទួលស្គាល់ថា តាមរយៈអ្នកតំណាងរបស់ខ្លួន បារាំងបានដើរតួនាទីជាប្រទេសម្ចាស់ផ្ទះ។

សេចក្តីពន្យល់ទាក់ទងនឹងដំណើរទស្សនកិច្ចរបស់ព្រះអង្គម្ចាស់ ដាម រ៉ុង ក្នុងនាមប្រទេសថៃ មិនអាចឱ្យតុលាការជឿជាក់បានទេ។ ដោយពិនិត្យមើលហេតុការណ៍ទាំងមូលឃើញថា មានការទទួលស្គាល់ដោយតុណ្ហីភាពរបស់សៀម ចំពោះអធិបតេយ្យរបស់កម្ពុជា (ក្រោមអាណាព្យាបាលបារាំង) លើប្រាសាទព្រះវិហារ ហើយតាមរយៈការខកខានរបស់សៀមមិនបានបញ្ចេញប្រតិកម្មតាមមធ្យោបាយណាមួយ នៅក្នុងកាលៈទេសៈដែលទាមទារឱ្យមានប្រតិកម្មដើម្បីបញ្ជាក់ឬការពារកម្មសិទ្ធិជាម្ចាស់ នៅចំពោះមុខនៃការទាមទារតបដោយជាក់ស្តែងនោះ។ អ្វីដែលហាក់ដូចជាច្បាស់លាស់នោះគឺថាការពិតសៀមមិនប្រាកដខ្លួនឯងថាខ្លួនមានកម្មសិទ្ធិនោះទេ -ហើយនេះគឺស្របគ្នាទាំងស្រុងទៅនឹងឥរិយាបថរបស់សៀមតាំងពីដើមមក និងក្រោយមកទៀតចំពោះផែនទីនិងខ្សែបន្ទាត់ឧបសម្ព័ន្ធ១ -ឬក៏បានសម្រេចថា មិនអះអាងនូវកម្មសិទ្ធិរបស់ខ្លួនទេ ដែលជាថ្មីម្តងទៀតនេះមានន័យថា ខ្លួនបាន

ព្រមទទួលយកការទាមទាររបស់បារាំងឬបានព្រមទទួលយកព្រំដែននៅព្រះវិហារ ដូចដែលបានគូសនៅក្នុងផែនទីនោះហើយ។

*

* *

អង្គហេតុពាក់ព័ន្ធទាំងឡាយដែលនៅសេសសល់ ត្រូវតែលើកយកមកនិយាយនាពេលនេះ។ នៅខែកុម្ភៈ ឆ្នាំ១៩៤៩ មិនយូរប៉ុន្មានបន្ទាប់ពីបានបញ្ចប់នីតិវិធីនៃគណៈកម្មការសម្រុះសម្រួលបារាំង-សៀម ដែលនៅក្នុងរយៈពេលដំណើរការគណៈកម្មការនោះ ជាក់ស្តែងថៃមិនបានលើកបញ្ហាព្រះវិហារទេ បារាំងបានផ្ញើកំណត់ទូតមួយជូនរដ្ឋាភិបាលថៃ ដោយបញ្ជាក់ថាខ្លួនបានទទួលរបាយការណ៍ស្តីពីការតាំងនៅនៃឆ្មាំសៀមចំនួន ៤ នាក់នៅប្រាសាទនេះ និងស្នើសុំឱ្យផ្តល់ព័ត៌មាន ។ ពុំមានការឆ្លើយតបចំពោះកំណត់ទូតនេះទេ ហើយក៏មិនមានការឆ្លើយតបទៅនឹងកំណត់ទូតមួយក្រោយមកទៀត នៅខែមីនា ឆ្នាំ១៩៤៩ ដែរ។ នៅខែឧសភា ឆ្នាំ១៩៤៩ បារាំងបានផ្ញើកំណត់ទូតមួយទៀតខ្លី ប៉ុន្តែមានន័យយ៉ាងច្បាស់អំពីមូលហេតុដែលបារាំងចាត់ទុកថា ព្រះវិហារស្ថិតក្នុងប្រទេសកម្ពុជា និងចង្អុលបង្ហាញថាផែនទីដែលផលិតដោយថៃខ្លួនឯងក៏បានទទួលស្គាល់ហេតុការណ៍នេះ។ បារាំងបានស្នើសុំឱ្យដកឆ្មាំទាំងនោះចេញ។ បើទុកជាមានកំហុសនៅក្នុងកំណត់ទូតនេះក្តី ខ្លឹមសារនៃកំណត់ទូតនោះគឺថា មានការអះអាងបញ្ជាក់ដែលមិនអាចប្រកែកបានអំពីអធិបតេយ្យ។ កំណត់ទូតរបស់បារាំងនេះ ក៏ពុំទទួលបានការឆ្លើយតបដែរ។ នៅខែកក្កដា ឆ្នាំ១៩៥០ បារាំងបានផ្ញើកំណត់ទូតមួយបន្ថែមទៀត។ កំណត់ទូតនេះ ក៏នៅតែពុំទទួលបានការឆ្លើយតបដែរ។

នៅក្នុងកាលៈទេសៈទាំងនេះ នៅពេលទទួលបានឯករាជ្យឆ្នាំ១៩៥៣ កម្ពុជាបានស្នើបញ្ជូនឆ្មាំឬអ្នកយាមក្នុងនាមខ្លួនឯងទៅកាន់ប្រាសាទនេះ ដើម្បីជាការបញ្ជាក់ឬការរក្សាជំហររបស់ខ្លួន។ ប៉ុន្តែដោយឃើញថា ឆ្មាំថៃមានវត្តមាននៅទីនោះរួចហើយ ឆ្មាំកម្ពុជាក៏បានដកមកវិញ ហើយកម្ពុជាក៏បានផ្ញើកំណត់ទូតមួយចុះខែមករា ឆ្នាំ១៩៥៤ ទៅរដ្ឋាភិបាលថៃស្នើសុំព័ត៌មាន។ កំណត់ទូតនេះគ្រាន់តែទទួលបានការបញ្ជាក់ថាបានទទួលប៉ុណ្ណោះ ដោយគ្មានសេចក្តីពន្យល់អ្វីឡើយ។ សូម្បីតែមកដល់ពេលនេះក្តី ក៏ពុំមានការអះអាងជាផ្លូវការណាមួយអំពីការទាមទាររបស់ថៃដែរ។ នៅចុងខែមីនា ឆ្នាំ១៩៥៤ ដោយ

យល់ឃើញថា គ្មានការឆ្លើយតបជាដុំកំភួនចំពោះកំណត់ទូតរបស់ខ្លួនពីមុន រដ្ឋាភិបាលកម្ពុជាបានជូនដំណឹងទៅរដ្ឋាភិបាលថៃថា នៅពេលនេះកម្ពុជាស្នើសុំដាក់កងទ័ពកម្ពុជាមួយចំនួនជំនួសឆ្មាំឬអ្នកថែរក្សារបស់កម្ពុជាដែលបានដកចេញពីមុនមក។ នៅក្នុងកំណត់ទូតនេះ កម្ពុជាបាននិយាយយោងជាពិសេសទៅលើការសំអាងហេតុផលនៃការទាមទាររបស់កម្ពុជាដែលមាននៅក្នុងកំណត់ទូតរបស់បារាំង ខែឧសភា ឆ្នាំ១៩៤៩។ កំណត់ទូតរបស់កម្ពុជានេះក៏មិនបានទទួលការឆ្លើយតបដែរ។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាមិនបានបញ្ជូនទាហានទៅទីនោះទេ ហើយនៅខែមិថុនា ឆ្នាំ១៩៥៤ កម្ពុជាបានផ្ញើកំណត់ទូតបន្ថែមទៀតទៅប្រទេសថៃ ដោយបញ្ជាក់ថា តាមព័ត៌មានដែលបានទទួលគឺថា ទាហានថៃនៅកាន់កាប់ទីនោះរួចហើយ ហើយកម្ពុជាផ្អាកការបញ្ជូនទាហានរបស់ខ្លួនទៅទីនោះក្នុងគោលបំណងមិនធ្វើឱ្យស្ថានការណ៍ធ្ងន់ធ្ងរ។ កំណត់ទូតនោះក៏បន្តស្នើឱ្យថៃឬមួយដកទ័ពរបស់ខ្លួនចេញ ឬមួយក៏ផ្តល់ទស្សនៈរបស់ថៃស្តីពីបញ្ហានេះដល់កម្ពុជា។ កំណត់ទូតនេះក៏មិនបានទទួលការឆ្លើយតបដូចពីមុនដែរ។ ប៉ុន្តែ ទាហានរបស់ថៃ (ដែលតាមពិតតុលាការដឹងថាពួកទាំងនោះជាកម្លាំងប៉ូលីស) នៅតែមានវត្តមាននៅទីនោះដដែល។ ដូច្នេះជាថ្មីម្តងទៀត វាហាក់ដូចជាថាប្រទេសថៃ បើទុកជាមានវិធានការមួយចំនួននៅលើដីជាក់ស្តែង ក៏ថៃមិនបានត្រៀមបដិសេធការទាមទាររបស់បារាំង និងកម្ពុជាក្នុងកម្រិតការទូតទេ។

ពុំមានលិខិតការទូតបន្ថែមទៀត ត្រូវបានយកមកបង្ហាញតុលាការទេ។ ប៉ុន្តែជាយថាហេតុនៅឆ្នាំ១៩៥៨ មានសន្និសីទមួយត្រូវបានប្រារព្ធឡើងនៅទីក្រុងបាងកក រវាងប្រទេសថៃនិងកម្ពុជា ដើម្បីពិភាក្សាអំពីបញ្ហាមួយចំនួនទាក់ទងនឹងទឹកដីដែលមានជម្លោះរវាងរវាងភាគីទាំងពីររួមមានបញ្ហាព្រះវិហារផងដែរ។ តំណាងរបស់ថៃបានបដិសេធមិនពិភាក្សាលើទិដ្ឋភាពច្បាប់នៃបញ្ហានេះទេ ហើយការចរចាបានបរាជ័យ ហើយកម្ពុជាបានចាត់ការតាមនីតិវិធីនេះ។

*

* *

នៅពេលនេះ តុលាការនឹងធ្វើសេចក្តីស្នើសុំដោយដកស្រង់ចេញពីអង្គហេតុ ដូចមានខាងលើ។ បើទុកជាមានការសង្ស័យខ្លះចំពោះការព្រមទទួលយករបស់សៀមនូវផែនទី

នៅឆ្នាំ១៩០៨ ហើយដែលជាហេតុនាំឱ្យខ្លួនព្រមទទួលយកព្រំដែនដែលចង្អុលបង្ហាញលើផែនទីនោះ តុលាការដោយផ្អែកលើព្រឹត្តិការណ៍ជាបន្តបន្ទាប់យល់ឃើញថា ឥឡូវនេះតាមរយៈឥរិយាបថរបស់ខ្លួនថៃមិនត្រូវបានអនុញ្ញាតឱ្យអះអាងថា ខ្លួនមិនបានព្រមទទួលយកផែនទីនេះនោះទេ។ អស់រយៈពេល ៥០ឆ្នាំ ប្រទេសនេះបានទទួលផលប្រយោជន៍គ្រប់បែបយ៉ាងដែលអនុសញ្ញាឆ្នាំ១៩០៤ ផ្តល់ឱ្យខ្លួនយ៉ាងហោចណាស់ ក៏ផលប្រយោជន៍នៃព្រំដែនមួយដែលមានស្ថិរភាពដែរ។ តាមរយៈបារាំង កម្ពុជានិងបារាំង ជឿថាប្រទេសថៃទទួលយកផែនទីនេះ។ ដោយសារតែគ្មានភាគីណាមួយអាចអះអាងអំពីកំហុស ដូច្នេះវាមិនមានប្រយោជន៍អ្វីក្នុងការស្វែងយល់អំពីការជឿទុកចិត្តដែលអាស្រ័យលើការជឿជាក់ថាផែនទីនេះត្រឹមត្រូវឬមិនត្រឹមត្រូវនោះទេ។ ឥឡូវនេះ ដោយនៅតែបន្តលើកឡើងពីផលប្រយោជន៍ និងអាស្រ័យផលដែលទទួលបានពីដំណោះស្រាយនេះ ថៃមិនអាចបដិសេធថាខ្លួនមិនដែលជាភាគីយល់ព្រមចំពោះដំណោះស្រាយនេះបានទេ។

ទោះបីជាយ៉ាងណាក៏ដោយ តុលាការយល់ឃើញថា នៅឆ្នាំ១៩០៨-១៩០៩ ថៃពិតជាបានព្រមទទួលយកផែនទីឧបសម្ព័ន្ធ១ ថាជាលទ្ធផលនៃការងារកំណត់ព្រំដែនដែលជាហេតុនាំឱ្យខ្លួនទទួលស្គាល់ខ្សែបន្ទាត់នៅលើផែនទីនោះ ជាខ្សែព្រំដែនដែលអានុភាពនៃការព្រមទទួលយកនេះ គឺដាក់ព្រះវិហារស្ថិតក្នុងទឹកដីកម្ពុជា។ តុលាការយល់ឃើញបន្ថែមទៀតថា ប្រសិនបើពិនិត្យមើលជារួម ឥរិយាបថជាបន្តបន្ទាប់របស់ថៃ បញ្ជាក់និងគាំទ្រការព្រមទទួលយកពីដំបូងរបស់ខ្លួន ហើយថាសកម្មភាពជាក់ស្តែងរបស់ខ្លួនមិនគ្រប់គ្រាន់ដើម្បីបដិសេធការព្រមទទួលយកនេះបានទេ។ តាមរយៈឥរិយាបថរបស់ខ្លួន ភាគីទាំងពីរបានទទួលស្គាល់ខ្សែបន្ទាត់នេះ ជាមូលហេតុនាំឱ្យពួកគេពិតជាបានព្រមព្រៀងគ្នាចាត់ទុកខ្សែបន្ទាត់នេះ ជាខ្សែព្រំដែន ។

*

*　　　*

ឥឡូវនេះ តុលាការត្រូវពិចារណាលើបញ្ហាពីរទៀត។ ថៃអះអាងថា ចាប់តាំងពីឆ្នាំ១៩០៨ ហើយជាពិសេស រហូតដល់មានការវាស់វែងដោយខ្លួនឯង ឆ្នាំ១៩៣៤-១៩៣៥ ថៃជឿជាក់ថា ខ្សែព្រំដែននៅលើផែនទីត្រួតស៊ីគ្នានិងខ្សែបែងចែកទឹក ដូច្នេះហើយប្រសិន

បើថៃទទួលយកខ្សែព្រំដែននៅលើផែនទីនោះ ខ្លួនធ្វើដូច្នោះក៏ដោយសារមានជំនឿបែប នោះដែរ។ មានភស្តុតាងបញ្ជាក់ថា ការអះអាងបែបនេះពិតជាមិនស៊ីចង្វាក់គ្នាទាល់តែសោះ ជាមួយនឹងការអះអាងដែលថៃបានលើកឡើងយ៉ាងខ្លាំងក្លា និងស្រួចស្រាល់ថា សកម្មភាព នានាក្នុងការអនុវត្តអធិបតេយ្យ ជាក់ស្តែងបានបញ្ជាក់យ៉ាងច្បាស់នូវជំនឿរបស់ខ្លួនថា ខ្លួន មានអធិបតេយ្យលើតំបន់ប្រាសាទនេះ ៖ ប្រសិនបើថៃពិតជាយល់ច្រឡំអំពីខ្សែព្រំដែន ឧបសម្ព័ន្ធ១ មែននោះ - មានន័យថា ប្រសិនបើថៃយល់ថា ខ្សែព្រំដែនឧបសម្ព័ន្ធ១ចង្អុល បង្ហាញនូវខ្សែបែងចែកទឹកត្រឹមត្រូវនោះ - នោះខ្លួនច្បាស់ជាបានជឿថា តំបន់ប្រាសាទ នេះស្ថិតក្នុងទឹកដីកម្ពុជាយ៉ាងពិតប្រាកដ (ដោយផ្អែកលើមូលដ្ឋាននៃផែនទីដែលខ្លួនបាន ព្រមទទួលយកនោះ)។ ប្រសិនបើថៃមានជំនឿបែបនេះមែន ហើយជំនឿនេះបង្កប់នៅក្នុង រាល់ការអះអាង ដែលថាខ្លួនបានព្រមទទួលយកផែនទីឧបសម្ព័ន្ធ១នេះដោយសារតែខ្លួន គិតថាផែនទីនេះត្រឹមត្រូវ នោះសកម្មភាពរបស់ខ្លួននៅលើទីតាំងជាក់ស្តែងត្រូវបានចាត់ ទុកថាជាការរំលោភបំពានដោយចេតនាលើអធិបតេយ្យ (ផ្អែកលើការសន្និដ្ឋានដូចបាន រៀបរាប់ខាងលើ) ដែលធ្វើឱ្យមានការសន្មតថា ថៃបានដឹងថាកម្ពុជាកាន់កាប់តំបន់ប្រាសាទ នេះ។ សេចក្តីស្នើសុំគឺថា ថៃមិនអាចអះអាងថាខ្លួនមានការភ័ន្តច្រឡំក្នុងការព្រមទទួលយក ខ្សែព្រំដែនឧបសម្ព័ន្ធ១ ដែលជាការផ្ទុយស្រឡះទៅនឹងហេតុផលដែលខ្លួនបានផ្តល់ទាក់ទង នឹងសកម្មភាពជាក់ស្តែងរបស់ខ្លួនដូចជាថា ខ្លួនមានជំនឿបានកាន់កាប់អធិបតេយ្យក្នុង តំបន់នេះ។

គេអាចយល់ឃើញបន្ថែមបានថា បើទុកជាការលើកឡើងអំពីការភ័ន្តច្រឡំរបស់ ថៃអាចទទួលយកបានជាគោលការណ៍ក៏ដោយ ក៏ថៃគួរតែលើកឡើងភ្លាមបន្ទាប់ពីបាន ធ្វើការវាស់វែងដោយខ្លួនឯងលើតំបន់ជម្លោះនេះក្នុងឆ្នាំ១៩៣៤-១៩៣៥។ តាំងពីពេល នោះមក ថៃមិនអាចថាខ្លួនជាអ្នករងគ្រោះដោយការភ័ន្តច្រឡំណាមួយឡើយ។

*

* *

ជាចុងក្រោយ មានទិដ្ឋភាពមួយទៀតនៃរឿងក្តីនេះដែលចាំបាច់តុលាការត្រូវលើក

យកមកពិចារណា។ តុលាការយល់ឃើញថា ការព្រមទទួលយកផែនទីឧបសម្ព័ន្ធ១ ដោយភាគីទាំងពីរនាំឱ្យផែនទីនេះចូលទៅក្នុងដំណោះស្រាយសន្ធិសញ្ញា និងក្លាយជាផ្នែកមួយដែលមិនអាចកាត់ផ្តាច់បាននៃដំណោះស្រាយសន្ធិសញ្ញានេះ។ គេមិនអាចនិយាយបានថាដំណើរការនេះងាកចេញពី ឬអាចជាការរំលោភបំពានលើលក្ខខណ្ឌទាំងឡាយនៃអនុសញ្ញាឆ្នាំ១៩០៤ នោះបានទេ នៅរាល់ករណីដែលខ្សែព្រំដែននៅលើផែនទីងាកចេញពីខ្សែបែងចែកទឹក ដោយហេតុថា បើយោងទៅតាមការយល់របស់តុលាការពីបញ្ហានេះផែនទីត្រូវបានព្រមទទួលយកដោយភាគីទាំងពីរនៅឆ្នាំ១៩០៨ ហើយ (ទោះបីវាត្រូវឬមិនត្រូវគ្រប់ទិដ្ឋភាពទាំងអស់ទៅនឹងខ្សែបែងចែកទឹកពិតក៏ដោយ) និងក្រោយមកចាត់ទុកថាជាលទ្ធផលនៃការបកស្រាយដោយរដ្ឋាភិបាលទាំងពីរ អំពីការកំណត់ព្រំដែនដែលសន្ធិសញ្ញានេះតម្រូវឱ្យមាន។ ម៉្យាងទៀត នៅពេលនោះភាគីទាំងពីរបានសម្រេចយកការបកស្រាយមួយនេះនៃដំណោះស្រាយសន្ធិសញ្ញាដែលថា ក្នុងករណីមានការខុសគ្នាជាមួយនឹងខ្សែបែងចែកទឹក ខ្សែព្រំដែនដែលបានគូសនៅលើផែនទីនេះ មានអានុភាពលើសលប់លើបទប្បញ្ញត្តិផ្សេងទៀតរបស់សន្ធិសញ្ញា។ ប៉ុន្តែ បើទុកជានៅពេលនេះ តុលាការត្រូវបានស្នើសុំឱ្យដោះស្រាយបញ្ហា ស្តីពីការបកស្រាយធម្មតានៃសន្ធិសញ្ញាតែប៉ុណ្ណោះក៏ដោយ ក៏តុលាការចាត់ទុកថា ការបកស្រាយដែលត្រូវផ្តល់ឱ្យនឹងមានភាពដូចគ្នាតាមហេតុផលដូចតទៅ។

ជាទូទៅ នៅពេលដែលប្រទេសពីរកំណត់ព្រំដែនមួយជាមួយគ្នា គោលបំណងចម្បងមួយក្នុងចំណោមគោលបំណងឯទៀត គឺដើម្បីសម្រេចបានដំណោះស្រាយដែលមានស្ថិរភាពនិងជាស្ថាពរ។ វាមិនអាចធ្វើទៅរួចទេ ប្រសិនបើខ្សែបន្ទាត់ដែលត្រូវបានកំណត់ឡើងនេះអាចលើកមកចោទជាបញ្ហានៅពេលណាមួយក៏បាន ដោយផ្អែកតាមដំណើរការដែលចេះតែបើកចំហរហូត ហើយបើសិនជាការកែតម្រូវអាចធ្វើបាននៅពេលណាដែលរកឃើញថាមានភាពមិនត្រឹមត្រូវណាមួយដោយធៀបទៅនឹងបទប្បញ្ញត្តិណាមួយនៅក្នុងសន្ធិសញ្ញាមូលដ្ឋាននោះ។ ដំណើរការរបៀបនេះអាចបន្ត ដោយគ្មានទីបញ្ចប់ និងមិនអាចឈានដល់ដំណោះស្រាយជាស្ថាពរបានទេ ដរាបណាគេអាចនៅតែរកឃើញកំហុសដែលអាចកើតមាននោះ។ ព្រំដែនរបៀបនេះ ក្រៅពីគ្មានស្ថិរភាពអាចក្លាយជាព្រំដែនដែលមិនទៀងទាត់។ គេត្រូវតែសួរថា ហេតុអ្វីបានជាភាគីទាំងពីរបានព្រមព្រៀងធ្វើការកំណត់ព្រំដែន ហើយមិនគោរពយកតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញាដែលបញ្ជាក់ប្រាប់ថា ព្រំដែននៅក្នុង

តំបន់នោះគឺជាខ្សែបែងចែកទឹក។ មានសន្ធិសញ្ញាព្រំដែនជាច្រើនដែលមិនបានចែងអ្វីលើស ពីខ្សែបែងចែកទឹកឬខ្សែខ្នងភ្នំឡើយ ហើយដែលគ្មានចែងបទប្បញ្ញត្តិណាមួយសម្រាប់ការ កំណត់ព្រំដែនណាមួយជាការបន្ថែមទេ។ ភាគីនៅក្នុងរឿងក្តីនេះច្បាស់ជាមានហេតុផល ដើម្បីបន្តជំហានលើសពីនេះទៅទៀត។ ហេតុផលតែមួយគឺ ដោយសារតែគេចាត់ទុកការ ចង្អុលបង្ហាញខ្សែបែងចែកទឹកថាមិនគ្រប់គ្រាន់ ដើម្បីសម្រេចបាននូវភាពច្បាស់លាស់ និង ស្ថាពរ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ទើបគេងាកទៅរកការកំណត់ព្រំដែន និង ខ្សែបន្ទាត់នៅលើផែនទី។

កត្តាជាច្រើនទៀតគាំទ្រទស្សនៈដែលថា គោលបំណងចម្បងរបស់ភាគីទាំងពីរ ក្នុងដំណោះស្រាយព្រំដែននៅឆ្នាំ១៩០៤-១៩០៨ គឺដើម្បីសម្រេចឱ្យបាននូវដំណោះស្រាយ ច្បាស់លាស់និងស្ថាពរ។ តាមរយៈភស្តុតាងដែលបានដាក់ជូនតុលាការ និងតាមចម្លើយ របស់គូភាគីផ្ទាល់ វាច្បាស់ណាស់ថា នៅអំឡុងមុនឆ្នាំ១៩០៤ បញ្ហាទាំងមូលនៃព្រំដែនដ៏ វែងរវាងសៀមជាមួយឥណ្ឌូចិនបារាំង បានក្លាយជាបុព្វហេតុនៃភាពមិនច្បាស់លាស់ កង្វល់ និងអរិភាព ដែលបណ្តាលឱ្យកើតមានរឿងរ៉ាវ ដូចដែលបានរៀបរាប់នៅក្នុងឯកសារមួយ ដាក់ជូនតុលាការស្តីពីសភាពនៃ "ការកើនឡើងនៃភាពតានតឹង" នៅក្នុងទំនាក់ទំនងរវាង សៀមនិងបារាំង។ តុលាការអាចធ្វើសេចក្តីសន្និដ្ឋានដោយស្របច្បាប់ថា គោលបំណង សំខាន់ឬក៏អាចចាត់ទុកថា ជាគោលបំណងធំធេងនៃដំណោះស្រាយក្នុងអំឡុងឆ្នាំ១៩០៤-១៩០៨ (ដែលនាំមកនូវដំណោះស្រាយទូទៅនៃបញ្ហាព្រំដែនដែលនៅសេសសល់ទាំងអស់ រវាងប្រទេសទាំងពីរ) គឺដើម្បីបញ្ចប់សភាពតានតឹងនេះនិងដើម្បីសម្រេចបាននូវស្ថិរភាព ព្រំដែន ដោយឈរលើមូលដ្ឋាននៃភាពច្បាស់លាស់និងស្ថាពរ។

នៅក្នុងបុរេកថានៃសន្ធិសញ្ញាព្រំដែនបារាំង-សៀម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ ភាគីទាំងពីរបានប្រកាសថា ភាគីទាំងពីរមានឆន្ទៈ "ធានាឱ្យបាននូវដំណោះស្រាយចុងក្រោយ នៃរាល់បញ្ហាទាំងអស់ ទាក់ទងទៅនឹងព្រំដែនរួមឥណ្ឌូចិននិងសៀម"។ សក្ខីភាពមួយទៀត នៃឆន្ទៈដូចគ្នានេះ ត្រូវបានបង្ហាញនៅក្នុងចេតនាដែលចង់បានព្រំដែនធម្មជាតិនិងជាក់ស្តែង ដូចដែលមានភស្តុតាងច្រើនលើសលប់នៅក្នុងឯកសារ និងដែលត្រូវបានបង្ហាញដោយភាគី ទាំងពីរ។ ដូចដែលតុលាការបានរៀបរាប់ខាងលើ បើទុកជាការណ៍នេះដោយឯកឯងមិនមែន

ជាហេតុផលសម្រាប់ប្រកាន់ថា ព្រំដែនត្រូវតែដើរតាមខ្សែធម្មជាតិនិងជាក់ស្តែងក្តី ក៏ប៉ុន្តែការណ៍នេះពិតជាគាំទ្រទស្សនៈថា ភាគីទាំងពីរចង់បាននូវដំណោះស្រាយច្បាស់លាស់និងស្ថាពរតាមរយៈខ្សែធម្មជាតិនិងជាក់ស្តែង។

ទស្សនៈដូចគ្នានេះត្រូវបានគាំទ្រយ៉ាងខ្លាំងក្លា ដោយឥរិយាបថរបស់ភាគីទាំងពីរចំពោះព្រំដែននៅក្នុងសន្ធិសញ្ញាឆ្នាំ១៩២៥និង១៩៣៧។ ដោយមិនរាប់បញ្ចូលយ៉ាងជាក់លាក់នូវបញ្ហាព្រំដែនពីដំណើរការនៃការសើរើសន្ធិសញ្ញានានាពីមុនឡើងវិញ ដែលសន្ធិសញ្ញាឆ្នាំ១៩២៥និង១៩៣៧ បានអនុវត្តតាមនោះ ភាគីទាំងពីរបានស្តែងឱ្យឃើញនូវសារៈសំខាន់ដ៏ឧត្តុង្គឧត្តម ដែលគេបានផ្សារភ្ជាប់ទៅនឹងភាពស្ថាពរនៅក្នុងបញ្ហាព្រំដែននេះ។ ឥរិយាបថរបស់ភាគីទាំងពីរនៅក្នុងឆ្នាំ១៩២៥និង១៩៣៧ អាចត្រូវបានចាត់ទុកថាជាភស្តុតាងដោយត្រឹមត្រូវដែលថាភាគីទាំងពីរមានចេតនាដូចគ្នា គឺចង់បាននូវដំណោះស្រាយស្ថាពរនៅក្នុងអំឡុងឆ្នាំ១៩០៤-១៩០៨ ផងដែរ។

ការចង្អុលបង្ហាញខ្សែបែងចែកទឹកនៅក្នុងមាត្រា១នៃអនុសញ្ញាឆ្នាំ១៩០៤ គឺគ្រាន់តែជាមធ្យោបាយជាក់ស្តែងនិងងាយស្រួលប៉ុណ្ណោះ ក្នុងការរៀបរាប់នូវខ្សែព្រំដែនមួយប្រកបដោយសត្យានុម័ត ទោះជាតាមលក្ខខណ្ឌទូទៅក្តី។ ប៉ុន្តែ ពុំមានហេតុផលណាមួយដែលត្រូវយកមកពិចារណាថា ភាគីទាំងពីរបានឱ្យសារៈសំខាន់ពិសេសណាមួយទៅនឹងខ្សែបែងចែកទឹកបែបនេះទេ បើប្រៀបធៀបទៅនឹងសារៈសំខាន់ដែលមានអាទិភាព ពោលគឺផលប្រយោជន៍នៃដំណោះស្រាយស្ថាពរក្នុងការគោរពតាមខ្សែនៅលើផែនទី ដូចដែលត្រូវបានកំណត់និងត្រូវបានព្រមទទួលយកដោយភាគីទាំងពីររួចហើយ។ ហេតុដូចនេះតុលាការយល់ថា តាមទស្សនៈនៃការបកស្រាយសន្ធិសញ្ញាត្រូវសម្រេចយកខ្សែបន្ទាត់ព្រំដែនដូចដែលបានគូសនៅលើផែនទីក្នុងតំបន់ជម្លោះ។

*

* *

ដោយផ្អែកលើមូលហេតុទាំងឡាយដែលតុលាការយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីរបស់ខ្លួន តុលាការមិនចាំបាច់ពិចារណាថា តើនៅព្រះវិហារខ្សែព្រំដែននៅ

លើផែនទី ពិតជាត្រូវទៅនឹងខ្សែបែងចែកទឹកពិតប្រាកដនៅក្នុងតំបន់ទាំងនេះឬពិតជាត្រូវទៅនឹងឆ្នាំ១៩០៤-១៩០៨ ឬប្រសិនបើមិនដូច្នេះទេ តើខ្សែបែងចែកទឹកពិតប្រាកដនោះដើរបៀបណា។

*

* *

ជាចុងក្រោយ ដោយយោងលើសេចក្តីស្នើសុំឱ្យវិនិច្ឆ័យដែលបានដាក់ជូនតុលាការនៅពេលបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់ ដែលបានចង្អុលបង្ហាញនៅក្នុងសេចក្តីផ្តើមនៃសាលដីកានេះ តុលាការរកឃើញថា សេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី១និងទី២របស់កម្ពុជា ដែលសុំឱ្យប្រកាសនូវឋានៈតាមផ្លូវច្បាប់នៃផែនទីឧបសម្ព័ន្ធ១និងខ្សែព្រំដែននៅក្នុងតំបន់ជម្លោះអាចទទួលយកមកពិចារណាបានតែក្នុងលក្ខខណ្ឌថា សេចក្តីស្នើសុំឱ្យវិនិច្ឆ័យទាំងនេះ មានបញ្ជាក់ពីមូលហេតុ ហើយមិនមែនជាការទាមទារដែលត្រូវយកមកដោះស្រាយនៅក្នុងបញ្ញត្តិអនុវត្តនៃសាលដីកានេះទេ។ ម៉្យាងទៀត តុលាការរកឃើញថាក្រោយពីបានលើកឡើងនូវការទាមទាររបស់ខ្លួនពាក់ព័ន្ធនឹងអធិបតេយ្យលើព្រះវិហារ ថៃបានលើកឡើងនៅក្នុងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យរបស់ខ្លួនត្រឹមតែអំណះអំណាង និងការបដិសេធដែលជំទាស់ទៅនឹងការតវ៉ារបស់ភាគីម្ខាងទៀត ដោយទុកឱ្យតុលាការតាក់តែងពាក្យពេចន៍សមស្រប អំពីហេតុផលទាំងឡាយដែលតុលាការយកជាមូលដ្ឋានសម្រាប់ការវិនិច្ឆ័យរបស់ខ្លួន។

នៅចំពោះមុខ នៃបណ្តឹងទាមទារដែលបានដាក់ជូនមកតុលាការដោយប្រទេសកម្ពុជា និងថៃរៀងៗខ្លួនទាក់ទងនឹងអធិបតេយ្យលើព្រះវិហារដែលនាំឱ្យមានជម្លោះរវាងរដ្ឋទាំងពីរនេះ តុលាការគាំទ្រកម្ពុជា ដោយអនុលោមទៅតាមសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី៣របស់ខ្លួន។ តុលាការក៏គាំទ្រកម្ពុជាផងដែរ ទាក់ទងនឹងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី៤ស្តីពីការដកកងកម្លាំងយោធា។

ចំពោះសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី៥របស់កម្ពុជាអំពីការធ្វើបដិទាន តុលាការយល់ឃើញថា សំណើដែលបានលើកឡើងនៅក្នុងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យនេះ ពុំមែនជាការពង្រីកបន្ថែមលើបណ្តឹងទាមទារដើមរបស់កម្ពុជាទេ (ដែលនៅក្នុងករណីនេះ សំណើនេះ

មិនគួរត្រូវបានទទួលយកទេនៅពេលដែលសំណើនេះត្រូវបានស្នើជាលើកដំបូងនោះ)។ ប៉ុន្តែ ដូចសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី៤ដែរ សេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី៥ជាប់ពាក់ព័ន្ធទៅនឹងបណ្តឹងទាមទារអធិបតេយ្យដែលជាហេតុនាំទៅដល់ការធ្វើបដិទាន។ ម្យ៉ាងទៀត មិនមានភស្តុតាងជាក់ស្តែងត្រូវបានដាក់ជូនតុលាការ ដែលបង្ហាញជាវិជ្ជមានថាវត្ថុទាំងឡាយដែលបានលើកឡើងក្នុងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យនេះ ពិតជាត្រូវបានយកចេញពីប្រាសាទនិងតំបន់ប្រាសាទនេះដោយថៃ ចាប់តាំងពីការកាន់កាប់របស់ថៃលើប្រាសាទនេះនៅឆ្នាំ១៩៥៤នោះទេ។ ជាការពិតហើយដែលថា ថៃមិនបានបដិសេធខ្លាំងក្លាទេចំពោះការចោទប្រកាន់នេះ ដែលខ្លួនមិនទាំងបានជំទាស់ថា សំណើនេះមិនអាចទទួលយកបាននោះផង។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ក្នុងកាលៈទេសៈបែបនេះ បញ្ហានៃការធ្វើបដិទាន គឺជាបញ្ហាមួយដែលតុលាការគ្រាន់តែអាចដោះស្រាយជាគោលការណ៍ដោយគាំទ្រកម្ពុជា ដោយមិនបញ្ជាក់អំពីវត្ថុណាមួយពិតប្រាកដនោះទេ។

**ផ្អែកលើសំអាងហេតុទាំងនេះ**

**តុលាការ**

**ដោយមានសំឡេង៩ទល់នឹង៣**

សម្រេចថា ប្រាសាទព្រះវិហារស្ថិតក្នុងទឹកដី ក្រោមអធិបតេយ្យរបស់ប្រទេសកម្ពុជា។

សម្រេចបន្ទាប់មកទៀតថា

**ដោយមានសំឡេង៩ទល់នឹង៣**

ប្រទេសថៃមានកាតព្វកិច្ចដកកងកម្លាំងទ័ព ឬប៉ូលីស ឬអ្នកថែរក្សា ឬឆ្មាំដទៃទៀតដែលថៃបានដាក់ក្នុងប្រាសាទឬក្នុងតំបន់ក្បែរប្រាសាទដែលស្ថិតក្នុងទឹកដីកម្ពុជា។

**ដោយសំឡេង៧ទល់នឹង៥**

សម្រេចថា ប្រទេសថៃមានកាតព្វកិច្ចប្រគល់មកឱ្យប្រទេសកម្ពុជាវិញ នូវវត្ថុទាំងឡាយតាមប្រភេទដែលបានបញ្ជាក់នៅក្នុងសេចក្តីស្នើសុំឱ្យវិនិច្ឆ័យទី៥របស់កម្ពុជា ដែលត្រូវបានយកចេញពីប្រាសាទឬតំបន់ប្រាសាទដោយអាជ្ញាធរពាក់ព័ន្ធរបស់ថៃ ចាប់តាំងពីកាលបរិច្ឆេទនៃការកាន់កាប់ប្រាសាទនេះដោយប្រទេសថៃ នៅឆ្នាំ១៩៥៤។

ធ្វើជាភាសាអង់គ្លេសនិងភាសាបារាំង។ អត្ថបទភាសាអង់គ្លេសយកជាផ្លូវការ។ ធ្វើនៅ

វិមានសន្តិភាពក្រុងឡាអេ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ជា៣ច្បាប់ មួយច្បាប់រក្សាទុកនៅបណ្ណសារដ្ឋានរបស់តុលាការ និងច្បាប់ដទៃទៀតបញ្ជូនទៅរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលថៃរៀងៗខ្លួន។

ប្រធាន

(ហត្ថលេខា) B. WINIARSKI

ក្រឡាបញ្ជី

(ហត្ថលេខា) GARNIER-COIGNET

## សាលដីកានេះ
## ត្រូវបានរៀបចំបកប្រែជាភាសាខ្មែរតាមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់
## ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងក្រោម
បានចូលរួមយ៉ាងសកម្មក្នុងការងារបកប្រែនេះ ÷

### បកប្រែដោយ ៖

| | | |
|---|---|---|
| ១- លោក | **ម៉ុង មុន្នីចរិយា** | ចៅក្រមតុលាការកំពូល |
| ២- លោក | **យូរ ឧត្តរា** | ចៅក្រមតុលាការកំពូល |

### ពិនិត្យកែសម្រួលដោយ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម | **ហេងវង្ស ប៊ុនឆាត** | ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ |
| ២- ឯកឧត្តម | **វ៉ា គឹមហុង** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន |
| ៣- បណ្ឌិត | **ជា វ៉ាន់ដេត** | ទីប្រឹក្សាឯកឧត្តម **សុខ អាន** |
| ៤- ឯកឧត្តម | **គឹករ៉ែត សំរេច** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ៥- បណ្ឌិត | **ចាប សុថារិទ្ធ** | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យលោកជំទាវ **ម៉ែន សំអន** |
| ៦- បណ្ឌិត | **គីម រ័ត្នវិសិដ្ឋ** | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តម **សុខ អាន** |
| ៧- បណ្ឌិត | **ស៊ុំ ម៉ាប់** | ទីប្រឹក្សាឯកឧត្តម **សុខ អាន** |

| | | |
|---|---|---|
| ៨- ឯកឧត្តម | **កេត សោផាន់** | ជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** |
| ៩- លោក | **ឡូន ស៊ីផាន់** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនៃទីស្ដីការគណៈរដ្ឋមន្ត្រី |
| ១០- លោក | **ជាប សន្តារតន៍** | ជំនួយការឯកឧត្តម **សុខ អាន** |
| ១១- បណ្ឌិត | **ម៉ម អំណាត់** | ជំនួយការខុទ្ទកាល័យឯកឧត្តម**សុខ អាន** |
| ១២- បណ្ឌិត | **ហែម សុចិត្ត** | ជំនួយការខុទ្ទកាល័យឯកឧត្តម**សុខ អាន** |
| ១៣- លោក | **ង ឌុស្សី** | ជំនួយការខុទ្ទកាល័យឯកឧត្តម**សុខ អាន** |
| ១៤- បណ្ឌិត | **ឆាំង ហ៊ុយ** | ជំនួយការខុទ្ទកាល័យឯកឧត្តម**សុខ អាន** |
| ១៥- លោក | **គង់ ច័ន្ទវាសនា** | ជំនួយការខុទ្ទកាល័យឯកឧត្តម**សុខ អាន** |
| ១៦- លោក | **ស៊ិន សុធា** | ជំនួយការឯកឧត្តម **វ៉ា គឹមហុង** |
| ១៧- លោក | **ខន ដានិត** | មន្ត្រីនៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន |

## អ្នកជំនាញផ្នែកច្បាប់

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឡាំ ជា** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងជាអនុប្រធានលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន |
| ២- ឯកឧត្តម | **ផូង សំភី** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងជាអគ្គនាយកបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| ៣- ឯកឧត្តម | **អ៊ឹម ស៊ីថុល** | ទីប្រឹក្សាលោកជំទាវ **ម៉ែន សំអន** |
| ៤- ឯកឧត្តម | **ស៊ា ម៉ៅ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ |

## ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធដោយគណៈកម្មការភាសាវិទ្យាខ្មែរ
## ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សូ មុយឃៀង** | ៦- ឯកឧត្តម | **ស៊ឹង ផុស** |
| ២-ឯកឧត្តម | **ច័ន្ទ សំណាញ** | ៧- លោក | **ថាច់ សែម** |
| ៣-ឯកឧត្តម | **ឆយ អូន** | ៨- លោក | **ម៉ុម ម៉ុន** |
| ៤- ឯកឧត្តម | **អ៊ុច ច័ន** | ៩- លោក | **យៀង វីរបុត្រ** |
| ៥-ឯកឧត្តម | **ម៉ុញ សារី** | ១០- លោក | **ទូច គឹមស្រ៊ាង** |

## គណៈសារគមនាគមន៍និងព័ត៌មាន
## អង្គភាពព័ត៌មាននិងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី

| | | |
|---|---|---|
| ១-ឯកឧត្តម | **ស្វាយ ស៊ីថា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ២-ឯកឧត្តម | **កែវ រ៉េមី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ៣-ឯកឧត្តម | **ផៃ ស៊ីផាន** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤-ឯកឧត្តម | **អ៊ុន ប៊ុណ្ណារ៉ា** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ៥-ឯកឧត្តម | **សុខ សាធ** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី |
| ៦-ឯកឧត្តម | **សម សុគន្ធា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ៧-ឯកឧត្តម | **ប៉ែន ខឿន** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី |
| ៨-លោកជំទាវ | **មាសសាឯម ដានី** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ៩-លោកជំទាវ | **សុខ វិឡាយ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី |
| ១០-ឯកឧត្តម | **ទិត សុធា** | ទីប្រឹក្សារាជរដ្ឋាភិបាល |

| | | |
|---|---|---|
| ១១-ឯកឧត្តម | **ញឹក វណ្ណារ៉ា** | ទីប្រឹក្សារាជរដ្ឋាភិបាល |
| ១២-ឯកឧត្តម | **ស៊ិន សារុន** | ឧត្តមមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី |
| ១៣-ឯកឧត្តម | **អ៊ឹង មល្លីវណ្ណា** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី |
| ១៤-ឯកឧត្តម | **សោម អូន** | ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី |
| ១៥-ឯកឧត្តម | **ថៅ វាសនា** | ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី |
| ១៦-បណ្ឌិត | **សៅ ស៊ីសុវណ្ណា** | ប្រធាននាយកដ្ឋានសារគមនាគមន៍ |
| ១៧-លោក | **សេង សាវ៉ន** | ប្រធាននាយកដ្ឋានកណ្តាល |
| ១៨-លោក | **ឱម ច័ន្ទតារ៉ា** | ប្រធាននាយកដ្ឋានព័ត៌មាន |
| ១៩-លោក | **អេត និត** | អនុប្រធាននាយកដ្ឋានសារគមនាគមន៍ |
| ២០-លោក | **សេង ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានសារគមនាគមន៍ |
| ២១-លោក | **នូ សាវុធឌី** | អនុប្រធាននាយកដ្ឋានសារគមនាគមន៍ |
| ២២-លោក | **ឡុង សុគុណា** | អនុប្រធាននាយកដ្ឋានសារគមនាគមន៍ |
| ២៣-លោក | **រស់ ឌីណា** | អនុប្រធាននាយកដ្ឋានសារគមនាគមន៍ |